# មជ្ឈមណ្ឌលឯកសារកម្ពុជា

**PTI0085**

## សម្ភាសន៍ជាមួយឈ្មោះ ង៉ែត សុខខឿន ភេទស្រី អាយុ៤៨ឆ្នាំ

មុខងារជំនាន់ខ្មែរក្រហម«យោធា»

ស្រុកកំណើតនៅភូមិត្រពាំងឈូក ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ

រស់នៅភូមិចំការជ្រៃខាងត្បូង ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់

ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០១:០៩:០២

៣៥ទំព័រ

វណ្ណៈ: ចឹងថ្ងៃហ្នឹងថ្ងៃទី២៣ខែ៥ឆ្នាំ២០១១ ចឹងជាដំបូងខ្ញុំចង់ប្រាប់ឈ្មោះខ្ញុំថា ខ្ញុំឈ្មោះសុខ វណ្ណៈ មីង ។

សុខខឿនៈ ចាស ។

វណ្ណៈ: មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំមកនេះចង់ចងក្រងឯកសារជាប្រវត្តិសាស្ត្រ ទុកជាប្រវត្តិសាស្ត្រដែលបងប្អូនយើងធ្លាប់ឆ្លងកាត់ពីមុនៗមកណាមីង?

សុខខឿនៈ ចាស ។

វណ្ណៈ: ចឹងបទសម្ភាសខ្ញុំជាមីងដែលទាក់ទងនិងរឿងរ៉ាវកន្លងមកហ្នឹង តើមីងអនុញ្ញាតឲ្យខ្ញុំយកទៅប្រើប្រាស់ដើម្បីទុកឲ្យក្មេងជំនាន់ក្រោយបានដឹងបានឮបានទេមីង?

សុខខឿនៈ ចុះមានអី ។

វណ្ណៈ: បាទ!ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង មីងឈ្មោះអីដែរ?

សុខខឿនៈ ង៉ែត សុខខឿន ។

វណ្ណៈ: អាយុប៉ុន្មានហើយមីង?

សុខខឿនៈ អាយុ៤៨ ។

វណ្ណៈ: ប្ដីមីងឈ្មោះអី?

សុខខឿនៈ កាន់ថា ។

វណ្ណៈ: គាត់អាយុប៉ុន្មានមានដឹងទេ?

សុខខឿនៈ អាយុ៤៩ ។

វណ្ណៈ: មីងមានកូនប៉ុន្មាន?

Documentation Center of Cambodia
Searching for the Truth: Memory & Justice
ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

សុខខឿនៈ ខ្ញុំមានកូន៤ ។

វណ្ណៈ មានកូន៤នាក់?

សុខខឿនៈ ចាស ។

វណ្ណៈ ស្រីប៉ុន្មាន?

សុខខឿនៈ ស្រីបីប្រុសមួយ ។

វណ្ណៈ ឪពុកមីងឈ្មោះអីដែរ?

សុខខឿនៈ ឈ្មោះ ទូច ជា ។

វណ្ណៈ ម្តាយមីង?

សុខខឿនៈ ឈ្មោះ ង៉ែត ហួន ។

វណ្ណៈ ចឹងសព្វថ្ងៃនេះគាត់ទាំងពីនៅដែរ?

សុខខឿនៈ គាត់ស្លាប់អស់ហើយ ។

វណ្ណៈ បងប្អូនមីងមានប៉ុន្មាននាក់?

សុខខឿនៈ មាន៧នាក់ ។

វណ្ណៈ មានស្រីប៉ុន្មាន?

សុខខឿនៈ ស្រីបួន ។

វណ្ណៈ ចឹងរាល់ថ្ងៃមករស់នៅខាងស្រុកហ្នឹងដែលឬមួយនៅស្រុក?

សុខខឿនៈ នៅស្រុកនោះអូន ។

វណ្ណៈ បាទ ។

សុខខឿនៈ មកខ្ញុំតែឯងមកនៅស្រុកនេះ ។

វណ្ណៈ នៅរស់ទាំងអស់គ្នា?

សុខខឿនៈ ស្លាប់ពីរ ។

វណ្ណៈ ស្លាប់នៅសម័យណាមីង?

សុខខឿនៈ សម័យអាពតនោះមួយ ។

វណ្ណៈ ស្លាប់សម័យប៉ុល ពតឈ្មោះអី?

សុខខឿនៈ ឈ្មោះ ប្រុស ។

វណ្ណៈ ឈ្មោះ ប្រុស?

សុខខឿនៈ ចាស ។

វណ្ណៈ ស្លាប់ដោយសារអីមីងមានដឹងទេ?

សុខខឿនៈ អត់បានដឹងផងបែកគ្នាហើយស្លាប់ ។

វណ្ណៈ ស្រុកកំណើតមីងនៅភូមិអីគេ?

សុខខឿនៈ នៅភូមិត្រពាំងឈូក ។

វណ្ណៈ ឃុំ?

សុខខឿនៈ ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ ។

វណ្ណៈ ចឹងសព្វថ្ងៃនេះមីងនៅភូមិអី?

សុខខឿនៈ នៅចំការជ្រៃខាងត្បូង ។

វណ្ណៈ ឃុំ?

សុខខឿនៈ ឃុំអន្លង់រាប ។

វណ្ណៈ ស្រុកវាលវែង?

សុខខឿនៈ ចាស ។

វណ្ណៈ ខេត្តពោធិសាត់មីង?

សុខខឿនៈ ចាស ។

វណ្ណៈ មីងសព្វថ្ងៃប្រកបមុខរបរអីដែរ?

សុខខឿនៈ ធ្វើចំការ ។

វណ្ណៈ កាលនៅតូចមីងរៀនដល់ថ្នាក់ណាដែរ?

សុខខឿនៈ អត់មានបានរៀនផង ។

វណ្ណៈ ចឹងមីងអត់ចេះអក្សរទេ?

សុខខឿនៈ អត់ចេះ ។

វណ្ណៈ យ៉ាងម៉េចបានជាមីងមិនបានរៀន?

សុខខឿនៈ ខ្ញុំធំដឹងក្តីឡើងខ្ញុំអាយុ១៧ទៅ១៨ហើយ ដល់ពេលហ្នឹងយន្តហោះទម្លាក់ម៉ែអត់ឲ្យទៅរៀន ខ្លាចបែកគ្នា ។

វណ្ណៈ ចឹងធំដឹងក្តីឡើងសង្គ្រាមតែម្តង?

សុខខឿនៈ ចាស ។

វណ្ណៈ យន្តហោះទម្លាក់ហ្នឹងឆ្នាំណាមីងមានដឹងទេ?

សុខខឿនៈ អត់មានចាំផង នៅតូចៗដែរ ។

វណ្ណៈ នៅតូចៗទេ ចឹងមីងគ្រាន់ដឹងថាមានយន្តហោះទម្លាក់ក្នុងសម័យលន់ នល់អីចឹង?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងនៅឆ្នាំ៧៥ ខ្មែរក្រហមវៃចូលទីក្រុងភ្នំពេញ ខ្មែរក្រហមទទួលជ័យជំនះបានទូទាំងប្រទេស ហ្នឹងមីងធ្វើអីវិញ?

សុខខឿនៈ ខ្ញុំចេញពីផ្ទះតាំងពីឆ្នាំ៧៣នោះ ។

វណ្ណៈ ចឹងចេញតាំងពីឆ្នាំ៧៣?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹង៧៣ពេលសង្គ្រាមហ្នឹង?

សុខខឿនៈ ៧៣សង្គ្រាមហើយ ។

វណ្ណៈ ចេញទៅណា?

សុខខឿនៈ ខ្ញុំចេញមកកន្លែងកុមារយោធា កន្លែងមន្ទីរ ។

វណ្ណៈ កាលហ្នឹងមីងអាយុប៉ុន្មាន?

សុខខឿនៈ ខ្ញុំ១៨ ។

វណ្ណៈ មិនទាន់ទេ កាល៧៣មីងអាយុច្រើនម្ល៉េះ នៅតូចៗទេកាលហ្នឹង?

សុខខឿនៈ ខ្ញុំអត់មានតូចប៉ុន្មានទេ ខ្ញុំចូលមកតាំងពីឆ្នាំ៧៣នោះ ។

វណ្ណៈ ប្រហែលជាមិនទាន់១៨ទេ បើឥឡូវមីងទើប៤០ជាងហ្នឹង កាលហ្នឹងមីងនៅកុមារនៅឡើយ មិនចូលជាកងចល័តយុវជនទេ?

សុខខឿនៈ ខ្ញុំកងចល័តខ្ញុំមិនដែលចូលទេ តែខ្ញុំចូលមកអគ្គភាពហ្នឹង ខ្ញុំចូលមកចូលកន្លែងយោធានិងតែម្តង អ៊ីខ្ញុំយកទៅកន្លែងហ្នឹងតែម្តង ។

វណ្ណៈ ចឹងមីងគិតមើល មីងនៅជារបៀបកុមារឬមួយមីងនៅជានារីពេញហើយ?

សុខខឿនៈ អត់ទេ នៅកុមារហ្នឹង ។

វណ្ណៈ ចឹងនៅជាកុមារប្រហែលជា១២ទៅ១៣ឆ្នាំហ្នឹងតាមមើល?

សុខខឿនៈ ប្រហែលជាប៉ុណ្ណឹងហើយតាមមើលនោះ ។

វណ្ណៈ ចឹងគិតមកដល់ឥឡូវប្រហែលជា៤០ជាងត្រូវ បើកាលហ្នឹងមីងអាយុ១៨ឆ្នាំនៅឆ្នាំ៧៣មកដល់ឥឡូវទាល់តែ៥០ជាង?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងនៅអគ្គភាពកុមារ?

សុខខឿនៈ នៅអគ្គភាព ។

វណ្ណៈ នៅអគ្គភាពកុមារហ្នឹងគេធ្វើអីខ្លះ?

សុខខឿនៈ ដឹងធ្វើអីកន្លែងកុមារនិងបើមិនដែលឃើញធ្វើអីផងនៅតែកន្លែងមន្ទីរហ្នឹង ។

វណ្ណៈ នៅកន្លែងមន្ទីរហ្នឹងមានរត់សំបុត្រអីទេ?

សុខខឿនៈ រត់តើ ។

វណ្ណៈ រត់សំបុត្រពីណាទៅណា?

សុខខឿនៈ រត់ពីកន្លែងមួយ គេឲ្យយកសំបុត្រចឹងទៅយកទៅឲ្យតាមមន្ទីរគេ ។

វណ្ណៈ បាទ!ចឹងកាលហ្នឹងមីងនៅកុមារអាយុប្រហែលជា១២-១៣ឆ្នាំទេចឹង?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងកន្លែងមន្ទីរកុមារហ្នឹងនៅម្តុំណាដែរ នៅស្រុកឬមួយនៅឃុំ?

សុខខឿនៈ ខ្ញុំចេញមកនៅស្រុកគេនេះ ។

វណ្ណៈ ស្រុកណា?

សុខខឿនៈ ជិតតាកែវ គេថាស្ទឹងកន្លែងហ្នឹង ។

វណ្ណៈ ចឹងមន្ទីរកុមារនៅស្រុក?

សុខខឿនៈ ចាស ។

វណ្ណៈ រត់សំបុត្រឲ្យពីណាគេ?

សុខខឿនៈ ឲ្យមន្ទីរស្រុកមន្ទីរតំបន់អីហ្នឹង ។

វណ្ណៈ រត់សំបុត្រឲ្យមន្ទីរស្រុក?

សុខខឿនៈ ចាស!តាមឃុំតាមខេត្តគេហ្នឹង ។

វណ្ណៈ ចឹងរត់ពីស្រុកទៅតំបន់?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងមានទៅភូមិឃុំទៀត?

សុខខឿនៈ ចាស!ភូមិឃុំគេតាមហ្នឹង ។

វណ្ណៈ ពួណាអ្នកឲមីងរត់សំបុត្រហ្នឹង ឈ្មោះអី?

សុខខឿនៈ ប្រធានមន្ទីរ ។

វណ្ណៈ ប្រធានមន្ទីរឈ្មោះអី?

សុខខឿនៈ ឈ្មោះ តា ចុក ។

វណ្ណៈ តា ចុងឬតាចុក?

សុខខឿនៈ តា ចុក ។

វណ្ណៈ តា ចុកហ្នឹងកូនតា ម៉ុកឬមួយមិនមែនទេ?

សុខខឿនៈ អត់ដឹងផង ។

វណ្ណះ   មីងស្គាល់តា ម៉ុកទេ?

សុខខឿនៈ ស្គាល់ ។

វណ្ណះ   ស្គាល់ដែរ?

សុខខឿនៈ ចាស ។

វណ្ណះ   តា ចុកបញ្ជាឲ្យរត់សំបុត្រចឹងកន្លែងមីងហ្នឹងមានគ្នាប៉ុន្មាននាក់ដែលអ្នករត់សំបុត្រហ្នឹង?

សុខខឿនៈ គ្នាច្រើនមានគ្នា១០ទៅ២០នោះនាក់នោះ ។

វណ្ណះ   ចឹងគ្នា២០នាក់?

សុខខឿនៈ ចាស ៗ !មួយមន្ទីរហ្នឹងច្រើនដែរ ។

វណ្ណះ   មានប្រុស ៗ ទេ?

សុខខឿនៈ មាន មានកុមារកុមារី ។

វណ្ណះ   ចឹងគេហៅកុមារកុមារីមិនហៅយុវជនទេ?

សុខខឿនៈ នៅ ។

វណ្ណះ   ចឹងនៅតូច ៗ ចឹងគេបំបែកពីឪពុកម្តាយ ហើយគេមិនឲ្យនៅជាមួយឪពុកម្តាយទេចឹង?

សុខខឿនៈ ខ្ញុំគេអត់មានបំបែកទេ ខ្ញុំមកដោយចិត្តឯងតែម្តង ។

វណ្ណះ   ចឹង?

សុខខឿនៈ ចាស ។

វណ្ណះ   ចឹងមីងចូលដោយចិត្តឯងដល់ពេលចូលមកមីងអត់មានពេលទំនេរទៅលេងឪពុកម្តាយទេមែន ទេ?

សុខខឿនៈ អត់ទេ អត់ដែលបានទៅ ។

វណ្ណះ   មីងនៅហ្នឹងគេហៅតំបន់ប៉ុន្មានភូមិភាគអី?

សុខខឿនៈ នៅកន្លែងខ្ញុំនៅហ្នឹង ។

វណ្ណះ   បាទ ។

សុខខឿនៈ នៅកំពង់ស្ពឺផ្ទឹកខ្ពស់យើងនេះ ។

វណ្ណះ   មកខាងកំពង់ស្ពឺវិញ?

សុខខឿនៈ ចាស ។

វណ្ណះ   ចឹងចេញពីតាកែវមកខាងខេត្តកំពង់ស្ពឺហ្នឹងវិញ?

សុខខឿនៈ មកខាងខេត្តកំពង់ស្ពឺហ្នឹងវិញ ។

វណ្ណះ   ឆ្នាំណាចេញពីតាកែវមក?

សុខខឿនៈ ចេញពីតាកែវមកឆ្នាំ៧២ហ្នឹង ។

វណ្ណៈ៖ ឆ្នាំ៧៣មីងទើបចូលហ្នឹង?

សុខខឿនៈ ៧៣ចូល៧៤ហើយហ្នឹង ។

វណ្ណៈ៖ បាទ ។

សុខខឿនៈ ហ្នឹង៧៤ដល់៧៥ បានខ្ញុំឡើងមកកោះកុងនេះ ។

វណ្ណៈ៖ ចឹង៧៤មកកំពង់ស្ពឺ?

សុខខឿនៈ ចាស ។

វណ្ណៈ៖ ចឹងនៅកំពង់ស្ពឺហ្នឹងតំបន់ប៉ុន្មានមីងមានដឹងទេ?

សុខខឿនៈ អត់ស្គាល់តំបន់និងគេផង ។

វណ្ណៈ៖ ចឹងកាលមីងនៅតាកែវមីងមានដឹងថាតំបន់ប៉ុន្មានទេ?

សុខខឿនៈ ខ្ញុំភ្លេចភូមិគេហ្នឹងហើយ ។

វណ្ណៈ៖ អត់ទេ កាលហ្នឹងគេមានលេខតំបន់លេខភូមិភាគ ដូចជាភូមិភាគនិរតីអីចឹងណាស់?

សុខខឿនៈ ចាស ។

វណ្ណៈ៖ ចឹងកាលនៅតាកែវមីងស្គាល់តា ចុកហើយមីងមានស្គាល់ពីណាទៀតជាប្រធានគណៈស្រុក គណៈអីហ្នឹង?

សុខខឿនៈ ខ្ញុំអត់មានស្គាល់ផងស្គាល់តែតា ចុកហ្នឹង តា ចុងបងប្អូនគាត់ហ្នឹង ។

វណ្ណៈ៖ ចឹងឆ្នាំ៧៤មីងមកខាងកំពង់ស្ពឺ?

សុខខឿនៈ ចាស ។

វណ្ណៈ៖ ពេលមកខាងកំពង់ស្ពឺចឹងទៅធ្វើអីខាងកំពង់ស្ពឺហ្នឹង?

សុខខឿនៈ នៅកំពង់ស្ពឺខ្ញុំនៅកន្លែងមន្ទីរហ្នឹងក្មេងៗ គេប្រើឲ្យគាស់ចេកដាំ ។

វណ្ណៈ៖ ដាំចេកនិងរត់សំបុត្រដែរ?

សុខខឿនៈ ចាស ។

វណ្ណៈ៖ មន្ទីរហ្នឹងមន្ទីរលេខប៉ុន្មាន?

សុខខឿនៈ មន្ទីរស្រុក ។

វណ្ណៈ៖ អត់មានលេខទេ?

សុខខឿនៈ អត់ ។

វណ្ណៈ៖ រត់សំបុត្រពីណាទៅណា?

សុខខឿនៈ ពីមន្ទីរមួយទៅមន្ទីរមួយតាមមន្ទីរ ។

វណ្ណៈ ចឹងមកខាងកំពង់ស្ពឺហ្នឹងពីណាប្រធានវិញហើយ?

សុខខឿនៈ ពូ រី ។

វណ្ណៈ ចឹងពូ រីហ្នឹងគាត់នៅរស់ទេរាល់ថ្ងៃ?

សុខខឿនៈ បែកគ្នាអស់ហើយមិនដឹងជាគាត់នៅណា ។

វណ្ណៈ ចឹងតា ចុកមាននៅទេ?

សុខខឿនៈ តា ចុកស្លាប់ហើយ ។

វណ្ណៈ ស្លាប់ជំនាន់ណា?

សុខខឿនៈ ស្លាប់តាំងជំនាន់អាពតនោះ ។

វណ្ណៈ ថីបានគាត់ស្លាប់?

សុខខឿនៈ ដឹងយ៉ាងម៉េច ដឹងគេសម្លាប់គាត់ឬយ៉ាងម៉េចខ្ញុំអត់ដឹងដែរ ខ្ញុំបែកពីគាត់មក ។

វណ្ណៈ ចឹងមីងរត់សំបុត្រមានដែលបានជួបទាហានលន់ នល់អីទេកាលហ្នឹង កាលនៅរត់សំបុត្រហ្នឹង មីង?

សុខខឿនៈ អត់ដែលជួបផង ។

វណ្ណៈ កាល៧៤ហ្នឹងនៅសង្គ្រាមនៅឡើយទេ មិនទាន់ចប់ទេ?

សុខខឿនៈ នៅ៧៥ហ្នឹងក៏នៅសង្គ្រាមដែរ ៧៥ខ្ញុំមកកោះកុងនេះគេទើបទម្លាក់អាវុធក្រោយទេ ។

វណ្ណៈ ចឹងកាលឆ្នាំ៧៥មីងអត់មានបានចូលភ្នំពេញទេ?

សុខខឿនៈ អត់មានចូលនិងគេផង ។

វណ្ណៈ ចឹង៧៥ហ្នឹងមីងបានកាន់កាំភ្លើងហើយ?

សុខខឿនៈ ខ្ញុំកាន់កាំភ្លើងហើយ ។

វណ្ណៈ ពីណាជាអ្នកបញ្ជូនមីងមកកោះកុង?

សុខខឿនៈ កាលហ្នឹងគេបញ្ជូនមកភូមិភាគទ័ព កាលហ្នឹងកុមារទ័ពស្មើរៗគេថាក្មេងៗឈាមរាវឡើងមក ភូមិភាគ ។

វណ្ណៈ ភូមិភាគអីគេ?

សុខខឿនៈ ភូមិភាគកោះកុងយើងហ្នឹង ។

វណ្ណៈ ភូមិភាគកោះកុងហ្នឹងភូមិភាគអីគេទៅ?

សុខខឿនៈ មិនដឹងជាភូមិភាគអីគេឲ្យឡើងមកភូមិភាគៗចឹង ។

វណ្ណៈ ចឹងដល់មកកោះកុងហ្នឹងមីងធ្វើអីទៀត?

សុខខឿនៈ ដល់មកកោះកុងហ្នឹងតាមកងគ្រប់ខេត្តទាំងអស់មកជួបជុំគ្នានៅកោះកុងហ្នឹងតែម្ដងនៅវត្ត
សុវណ្ណសាគរនៅអន្លង់ទឹកហ្នឹង មកនៅមូលគ្នាហ្នឹងមកបែកកងបែកអីគ្នានៅហ្នឹង ។

វណ្ណៈ នៅវត្តសុវណ្ណសាគរ?

សុខខឿនៈ ចាស ។

វណ្ណៈ នៅអន្លង់ទឹក?

សុខខឿនៈ អន្លង់ទឹក ។

វណ្ណៈ កាលមកជុំគ្នាហ្នឹងមានគ្នារាប់រយនាក់ទេ?

សុខខឿនៈ មានច្រើនបើមនុស្សឡើងមកគ្រប់ខេត្តគ្រប់ឃុំទាំងអស់ មកលាយគ្នាគេរៀបចំកងថ្មីតែម្ដង
នៅហ្នឹងនោះ ។

វណ្ណៈ ប្រហែលជាប៉ុន្មាននាក់ដែរ?

សុខខឿនៈ ប្រហែលជា១០០០នាក់ដែលហ្នឹង មករៀបចំបែកកងថ្មីហើយបានរៀបចំតាមមុខសញ្ញាទៅ
តាមមុនសញ្ញាអស់ ។

វណ្ណៈ ចឹងមានចំរុះច្រើនខេត្តទៀត?

សុខខឿនៈ ច្រើន ។

វណ្ណៈ ចឹងនៅហ្នឹងមានពីណាជាអ្នកបែកកងបែកក្រុមអីចឹង?

សុខខឿនៈ ហ្នឹងអត់មានពីណា ដូចថាតាមកងវរៈឡើងមកវរៈនេះហ្នឹង វរៈទី១ទី២ឡើងមកកង១វរៈហ្នឹង
គេជួបជុំគ្នារំលាយចូលគ្នាហ្នឹងទៅបែកតាមសារថ្មីកងនេះទៅនៅនោះចឹងទៅ ។

វណ្ណៈ បាទ ។

សុខខឿនៈ ដូចយើងលាយគ្នា ។

វណ្ណៈ ចឹងមីងនៅកងវរៈប៉ុន្មាន?

សុខខឿនៈ ខ្ញុំនៅកងវរៈទី៣ មេកងឈ្មោះ ថុលមិនដឹងជីតាគាត់ឈ្មោះអី ឈ្មោះ ថុល ។

វណ្ណៈ កងវរៈទី៣ហ្នឹងវរៈសេនាធំឬសេនាតូច?

សុខខឿនៈ វរៈសេនាតូច ។

វណ្ណៈ ចឹងមីងនៅក្នុងវរៈសេនាធំលេខប៉ុន្មានមានចាំទេ?

សុខខឿនៈ លេខ៨ ។

វណ្ណៈ កងពលប៉ុន្មាន?

សុខខឿនៈ កងពលទី៥ ។

វណ្ណៈ ពីណាជាប្រធានកងពល?

សុខខឿនៈ បង រឿន ឈ្មោះ រឿន ។

វណ្ណៈ ឈ្មោះ រឿន?

សុខខឿនៈ ចាស ។

វណ្ណៈ គាត់មាននៅទេរាល់ថ្ងៃ?

សុខខឿនៈ ពីមុនគានៅស្រុកដល់ក្រោយមកឮថា ស្លាប់ដឹងយ៉ាងម៉េច បែកគ្នាទៅស្រុក ។

វណ្ណៈ រឿនហ្នឹងគាត់កាចទេ កាលហ្នឹង?

សុខខឿនៈ គាត់មិនកាចផង គាត់រៀងស្លូតដែរ ។

វណ្ណៈ ចឹងមីងរបបហូបចុកតាំងពីមីងចូលចលនារហូតដល់ទៅកោះកុងអីទៀតចឹងគឺអត់មានការខ្វះខាតទេឬមានខ្វះខាតដែរ?

សុខខឿនៈ ខ្ញុំនៅជួរទ័ពហ្នឹងអត់មានខ្វះខាតទេ ។

វណ្ណៈ ចឹងអាហារគ្រប់គ្រាន់?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងតា ម៉ុកអីមានដែលទៅដល់ហ្នឹងទេ?

សុខខឿនៈ គាត់ទៅមិនដែលដល់ទេ គាត់មកនៅម៉្តុំមួយពាន់បីនេះវិញ គាត់អត់ដែលចុះទៅកោះកុងហ្នឹងផង ។

វណ្ណៈ ចឹង?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងមីងស្គាល់តា ម៉ុកច្បាស់ទេ?

សុខខឿនៈ ខ្ញុំស្គាល់តើ ។

វណ្ណៈ ស្គាល់យ៉ាងម៉េចខ្លះទៅ?

សុខខឿនៈ ស្គាល់កន្លែងគាត់រស់នៅសកម្មភាពគាត់ ។

វណ្ណៈ តា ម៉ុកកាចទេបើតាមមីងដឹង?

សុខខឿនៈ ពាក្យសម្តីគាត់កាចដែលណា ប៉ុន្តែអាកប្បកិរិយាគាត់ដាក់លើប្រជាជនដាក់លើកម្មាភិបាលអីគាត់កាចតែកន្លែងយើងធ្វើខុស គាត់កាច បើថាយើងត្រូវគាត់អត់កាចទេគាត់និយាយតាមច្បាប់ ។

វណ្ណៈ គាត់ជាអ្នកស្រុកភូមិជាមួយមីងដែរ?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងមីងមានស្គាល់តា ទិត្យអីទេ?

សុខខឿនៈ ខ្ញុំស្គាល់គាត់ដែរ ។

វណ្ណៈ     តា ទិត្យយ៉ាងម៉េចដែរ តា ទិត្យគាត់ធ្វើអីកាលហ្នឹង?

សុខខឿនៈ តា ទិត្យកាលហ្នឹងគាត់ធ្វើគណៈស្រុកដែលហ្នឹងកាលពីមុនមក ។

វណ្ណៈ     គណៈស្រុកអីគេ?

សុខខឿនៈ តា ទិត្យដឹងនៅស្រុកណាខ្ញុំមិនដែលដឹងស្រុកទេសគាត់នៅផង បើថាស្រុកកំណើតគាត់នៅជិតគ្នាហ្នឹង ។

វណ្ណៈ     បាទ ។

សុខខឿនៈ តែគាត់មកធ្វើមិនដឹងថាមុំភូមិអី ។

វណ្ណៈ     ស្គាល់ប្រពន្ធគាត់ទេ?

សុខខឿនៈ ស្គាល់ ។

វណ្ណៈ     ប្រពន្ធគាត់ឈ្មោះអី?

សុខខឿនៈ ឈ្មោះ គឿន ។

វណ្ណៈ     ឈ្មោះ យាយ កេនទេ?

សុខខឿនៈ អះ!យាយ កេន យាយ គឿននោះប្អូនទេ យាយ គឿនហ្នឹងប្រពន្ធតា សាន ។

វណ្ណៈ     គាត់កូនប្រសាតា ម៉ុកឬមិនមែនទេ?

សុខខឿនៈ គាត់ប្អូនហ្នឹង ។

វណ្ណៈ     ចឹងយាយកេន ប្អូនតា ម៉ុក?

សុខខឿនៈ ចាស ។

វណ្ណៈ     ចឹងតា សាន?

សុខខឿនៈ តា សាននិងពិបាកប្រាប់ណាស់ តា សានហ្នឹងក៏ប្អូនថ្លៃគាត់ដែរ ប្អូនតា ម៉ុកហ្នឹង ។

វណ្ណៈ     ចឹងតា សាននិងប្អូនថ្លៃតា ម៉ុកដែរ?

សុខខឿនៈ ចាស ។

វណ្ណៈ     ចឹងតា សាននិងគាត់ធ្វើអីដែលកាលហ្នឹង?

សុខខឿនៈ តា សានហ្នឹងកាលពីមុនគាត់ធ្វើគណៈស្រុកដែលហ្នឹងសម័យបីឆ្នាំហ្នឹង ។

វណ្ណៈ     ចឹងគាត់នៅទេរាល់ថ្ងៃហ្នឹង?

សុខខឿនៈ រាល់ថ្ងៃហ្នឹងគាត់នៅសំឡូតឬនៅប៉ៃលិនរាល់ថ្ងៃហ្នឹងធ្វើធំដែលតើនៅទាំងប្ដីទាំងប្រពន្ធ ។

វណ្ណៈ     តា សានប្អូនថ្លៃតា ម៉ុក?

សុខខឿនៈ ចាស ។

វណ្ណៈ ប្រពន្ធតា សានឈ្មោះអី?

សុខខឿនៈ ឈ្មោះ គឿន ។

វណ្ណៈ ចឹងសព្វថ្ងៃគាត់នៅរស់ប៉ុន្តែមិនដឹងថាគាត់រស់នៅសំឡូតឬអន្លង់វែង?

សុខខឿនៈ ចាស!កាលមិនគាត់នៅអន្លង់វែងដែរ តែហើយគាត់មកសំឡូតតាមកូននោះហើយឥឡូវគាត់នៅណាខ្ញុំមិនសូវដឹង ។

វណ្ណៈ ចឹងតា ម៉ុកគាត់មានបងប្អូនកូនចៅច្រើន ចឹងកូនប្រសាតា ម៉ុកមានប៉ុន្មាននាក់មីងដឹងទេ?

សុខខឿនៈ កូនប្រសាគាត់កូនគាត់មានប៉ុន្មានដូចបួននាក់ ។

វណ្ណៈ កូនស្រីគាត់?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងតា ម៉ុកមានកូនស្រីតែបួននាក់ទេអត់មានកូនប្រុសទេ?

សុខខឿនៈ អត់មានទេ កូនគាត់មាន៥នាក់ ។

វណ្ណៈ ចឹងមាន៥នាក់?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងស្រីទាំងអស់?

សុខខឿនៈ ស្រីទាំងអស់ ។

វណ្ណៈ កូនប្រសាតា ម៉ុកទី១ឈ្មោះអី?

សុខខឿនៈ ទី១ឈ្មោះ តា វ៉ែន អះ!មិនមែនទេ ទី១ប្តីបងខុមមុនតា មុតយើងហ្នឹងទី២តា វិន ។

វណ្ណៈ ទី២ តា វិន?

សុខខឿនៈ ចាស ។

វណ្ណៈ ឈ្មោះអី វិនទៅ?

សុខខឿនៈ អត់ស្គាល់ដែរ ។

វណ្ណៈ តា វិនហ្នឹងនៅរស់ដែរ?

សុខខឿនៈ តា វិនហ្នឹងស្លាប់បាត់ហើយ ។

វណ្ណៈ ចឹងទី៣?

សុខខឿនៈ ទី៣ តា វ៉ែន ។

វណ្ណៈ តា វ៉ែនហ្នឹងស្លាប់ដែរ?

សុខខឿនៈ ចាស ។

វណ្ណៈ ទី៤?

សុខខឿនៈ តា បូរ៉ាន ។

វណ្ណៈ តា បូរ៉ាននិងនៅទេ?

សុខខឿនៈ ស្លាប់បាត់ហើយ ។

វណ្ណៈ យ៉ាងម៉េចស្លាប់សឹងទាំងអស់ហើយ ទី៥ ?

សុខខឿនៈ ទី៥ បងច្រិច ។

វណ្ណៈ ច្រិច ។

សុខខឿនៈ អា ច្រិច ប្ដីវាឈ្មោះអាឈ្មោះ អា គី អាគីចិនហើយជនជាតិប៉ុននៅរស់ទេឥឡូវនោះ ។

វណ្ណៈ ច្រិចហ្នឹង?

សុខខឿនៈ កូនពៅគាត់ ។

វណ្ណៈ និយាយកូនប្រសាប្រុសគាត់ឈ្មោះអីគេ?

សុខខឿនៈ ឈ្មោះ អា គី ។

វណ្ណៈ ឈ្មោះ គី?

សុខខឿនៈ ចាស ដឹងតែប្ដីគេមុនៗតែក្រោយមកមិនដឹងគេលែងគ្នាគេយកគ្នាយ៉ាងម៉េចខ្ញុំមិនដឹង ។

វណ្ណៈ ជនជាតិទេ ឈ្មោះហ្នឹង?

សុខខឿនៈ ជនជាតិ ។

វណ្ណៈ ជនជាតិអី?

សុខខឿនៈ ជនជាតិលាវដឹងអាហ្នឹងនោះ ។

វណ្ណៈ នៅរស់ទេ?

សុខខឿនៈ នៅរស់ ។

វណ្ណៈ នៅរស់នៅណា?

សុខខឿនៈ នៅសំឡូត ។

វណ្ណៈ ចឹងតា ម៉ុកគាត់មានបងប្អូនបង្កើតប៉ុន្មាននាក់ទៅដឹងទេ?

សុខខឿនៈ កូនបង្កើតគាត់មើលប្អូនទៅប្រាំនាក់ប្រាំមួយនាក់នោះ ។

វណ្ណៈ ចឹងបងប្អូនបង្កើតគាត់មាន៦នាក់?

សុខខឿនៈ ចាស ។

វណ្ណៈ នៅរស់ទាំងអស់?

សុខខឿនៈ មានស្លាប់ខ្លះ ។

វណ្ណៈ ស្លាប់មីងដឹងទេស្លាប់ប៉ុន្មាននាក់ និយាយបងប្អូនគាត់បង្កើត ស្លាប់មានយាយពូនអីហ្នឹង?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងអ្នកនៅរស់មានប៉ុន្មាននាក់?

សុខខឿនៈ អ្នកនៅរស់មានបីបួននាក់ ។

វណ្ណៈ បួននាក់?

សុខខឿនៈ មីងគួបដូចជាស្លាប់ដែលហើយ ។

វណ្ណៈ បួននាក់ទី១ពីណាគេអ្នកនៅរស់?

សុខខឿនៈ នៅរស់យាយ កេនមួយ ។

វណ្ណៈ ប្ដីឈ្មោះទិត្យ?

សុខខឿនៈ ចាស ។

វណ្ណៈ ឈ្មោះ អ៊ីទិត្យទៅ?

សុខខឿនៈ អត់ស្គាល់ដី តា គាត់ផង ។

វណ្ណៈ ចឹងទី២អ្នកនៅរស់ដែរ?

សុខខឿនៈ យាយ គឿន ។

វណ្ណៈ យាយ គឿន ប្ដីគាត់?

សុខខឿនៈ តា សាន ។

វណ្ណៈ តា សាននៅរស់ទេ?

សុខខឿនៈ នៅ ។

វណ្ណៈ ទី៣?

សុខខឿនៈ យាយ គួបប៉ុនគាត់ស្លាប់ហើយយាយខួបនោះ ។

វណ្ណៈ ប្ដីគាត់?

សុខខឿនៈ ប្ដីគាត់យកក្រោយមិនដឹងជាឈ្មោះអី ។

វណ្ណៈ ចុះប្ដីមុន?

សុខខឿនៈ ប្ដីមុនស្លាប់បាត់ហើយ ។

វណ្ណៈ ឈ្មោះអីគេ?

សុខខឿនៈ ខ្ញុំអត់ស្គាល់ផង ។

វណ្ណៈ ទី៤?

សុខខឿនៈ ហ្នឹងប៉ុន្មានហើយ?

វណ្ណៈ មើលយាយ កេន ។

សុខខឿនៈ យាយ គៀន យាយ គួប ។

វណ្ណៈ មានពីណាទៀត?

សុខខឿនៈ យាយ ពូន ។

វណ្ណៈ យាយ ពូនស្លាប់ហើយ ។

សុខខឿនៈ ចាស!យាយពូនស្លាប់ហើយ ។

វណ្ណៈ ចឹងអ្នកនៅរស់?

សុខខឿនៈ នៅរស់មានពីណាទៀត ។

វណ្ណៈ ចឹងតា ទិត្យនិងតា សាននិងនៅណាសព្វថ្ងៃ?

សុខខឿនៈ ថា ដូចជានៅសំឡូត ។

វណ្ណៈ ចឹងតា សាននៅសំឡូតដែរ?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងមីងគ្រួសារគាត់ច្បាស់ដែរ?

សុខខឿនៈ ខ្ញុំស្គាល់ ។

វណ្ណៈ នៅស្រុកភូមិជាមួយគ្នាមីង?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងតា សានកាលសម័យខ្មែរក្រហមគាត់ធ្វើអីដែរ?

សុខខឿនៈ ដឹងគាត់ធ្វើអីពុថា ធ្វើមេៗដឹងគាត់ធ្វើអី ។

វណ្ណៈ ចឹងថាតាចុង តា ចុងស្លាប់ហើយថាកូនប្រសាគាត់ដែរ?

សុខខឿនៈ គាត់ស្លាប់បាត់ហើយ ។

វណ្ណៈ ប្អូនថ្លៃ?

សុខខឿនៈ ប្អូនថ្លៃ ។

វណ្ណៈ ប្រធានគាត់ឈ្មោះអីតា ចុង?

សុខខឿនៈ ឈ្មោះ យាយ ហោ ។

វណ្ណៈ ស្លាប់ដោយសារមូលហេតុអីដែលតា ចុង?

សុខខឿនៈ គាត់ស្លាប់គេចាប់គាត់មិនដឹងអីមិនដឹងខ្ញុំមិនសួរដឹងដែរ ។

វណ្ណៈ បាទ ។

សុខខឿនៈ កាលចំបក់ហ្នឹងគេគឹងតែង ខ្ញុំនៅកោះកុងនេះ ។

វណ្ណៈ បាទ!ចឹងកាលមីងទៅកោះកុងហ្នឹងមានអ្នកគាកែវទៅជាមួយមីងច្រើនដែលឬមិនសូវមាន ទេ កាលហ្នឹង?

សុខខឿនៈ មិនសូវមានផង ។

វណ្ណៈ ចឹងមានអ្នកផ្សេងៗទេ?

សុខខឿនៈ ចាស!មានតែពីរបីនាក់ ។

វណ្ណៈ ចឹងមីងនៅកោះកុងតាំងពី៧៥រហូតដល់ពេលណា?

សុខខឿនៈ ៧៥-៧៦ដល់៧៧ខ្ញុំមកនៅស្រែអំបិលនេះវិញហើយ ។

វណ្ណៈ ចឹងកាលនៅកោះកុងធ្វើអីដែលកាលហ្នឹង?

សុខខឿនៈ កាលហ្នឹងខ្ញុំនៅជាទ័ពដល់ចេញពីទ័ពនិងមកគេបំបែកខ្ញុំឲ្យមកនៅខាងនេសាទ ចាប់ត្រីតាមសមុទ្រ ។

វណ្ណៈ ចឹងមីងចេះចាប់ត្រីដែរ?

សុខខឿនៈ ចេះដាក់តាមទូកយើងរាយម៉ងអីហ្នឹង ។

វណ្ណៈ កាលហ្នឹងមានត្រីច្រើនទេមីង?

សុខខឿនៈ កាលហ្នឹងត្រីច្រើនមិនមែនដូចឥឡូវទេ កាលហ្នឹងវាមានខ្សែភ្លើងឆក់ដូចឥឡូវណា ។

វណ្ណៈ បាទ ។

សុខខឿនៈ កាលហ្នឹងហ៊ានតែទម្លាក់មួយម៉ោង២ម៉ោងត្រីយកមិនរួចទេ ។

វណ្ណៈ ចឹងកាលមីងនៅខាងទ័ពមិនជួបការលំបាករឿងហូបចុកទេ តែមីងមានបានដឹងថាប្រជាជនអត់បាយហើយត្រូវគេយកទៅសម្លាប់មីងមានបានដឹងទេកាលហ្នឹង?

សុខខឿនៈ មានតើ តែតំបន់មីងនៅហ្នឹងមិនសូវឃើញគេធ្វើបាបប្រជាជនអត់បាយអត់ទឹកចឹងទេ ។

វណ្ណៈ បាទ ។

សុខខឿនៈ កន្លែងតំបន់មីងនៅហ្នឹងហូបចុកគ្រប់គ្រាន់ ។

វណ្ណៈ ចឹងគ្នាមីងមានចាប់ខ្លួនឬបាត់ខ្លួនដែរ?

សុខខឿនៈ ពេលមីងចេញពីហ្នឹងមក មកនៅអគ្គភាពបានឃើញមានសកម្មភាពគេធ្វើបាបអីចឹង គេចាប់គេចងអីចឹងមាន ។

វណ្ណៈ មីងចេញមកនៅណាវិញ?

សុខខឿនៈ មីងចេញពីកន្លែងនេសាទនិងមក មកនៅកន្លែងកាត់ដេរ មកនៅម្ដុំកងចល័ត ។

វណ្ណៈ កាត់ដេរនៅកោះកុងដដែល?

សុខខឿនៈ ចាស!នៅស្រែអំបិល៧៧ ។

វណ្ណៈ ៧៧ហ្នឹងមីងមកនៅស្រែអំបិលហើយ?

សុខខឿនៈ ចាស ។

វណ្ណៈ ស្រែអំបិលកំពតហ្នឹង?

សុខខឿនៈ ចាស ។

វណ្ណៈ ស្រែអំបិលកំពតឬស្រែអំបិលកោះកុង?

សុខខឿនៈ ស្រែអំបិលកោះកុងយើងហ្នឹង អណ្តូងទឹកស្រែអំបិលហ្នឹង ។

វណ្ណៈ ចឹងកោះកុងដែល?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងមីងធ្វើអីវិញមីងមកនៅស្រែអំបិលហ្នឹង?

សុខខឿនៈ កាលហ្នឹងបងប្អូនឯងគាត់នៅប្រធានមន្ទីរនិងទៅហើយ គាត់ហៅមីងមកពេលហៅមកចឹងគេមិនយកមីងមកកន្លែងកាត់ដេរនិងទេ គេយកមីងទៅដាក់កន្លែងកងចល័ត ។

វណ្ណៈ ចឹងមកស្រែអំបិលហ្នឹងមកនៅខាងកងចល័តវិញ?

សុខខឿនៈ ចាស ។

វណ្ណៈ កងចល័តនិងធ្វើអីខ្លះទៅ?

សុខខឿនៈ កងចល័តនិងគេឲ្យរែកដី ។

វណ្ណៈ ពីណាជាប្រធាននៅកន្លែងរែកដីហ្នឹង?

សុខខឿនៈ ឈ្មោះអីទេ ខ្ញុំភ្លេច..ឈ្មោះរុន ។

វណ្ណៈ ចឹងមីងនៅកងចល័តហ្នឹងលំបាកទេ?

សុខខឿនៈ នៅកងចល័តនិងលំបាកណាស់ បាយគេដួសឲ្យតែមួយវែកៗកំណត់ ។

វណ្ណៈ ឈ្មោះ រុននិងស្រីប្រុស?

សុខខឿនៈ រុន និងស្រីទេ ប្រធានគេនៅគ្រប់គ្រងកងចល័តហ្នឹង ។

វណ្ណៈ កងចល័តមីងនៅហ្នឹងមានគ្នាច្រើននាក់ទេមានរាប់រយនាក់ទេ?

សុខខឿនៈ ច្រើនណាស់ ។

វណ្ណៈ ប្រហែលជាប៉ុន្មាននាក់ទៅ?

សុខខឿនៈ ប្រហែលជាចូលពាន់នាក់ទៅ ចេញចូលៗគេដកចេញគេដាក់ចូល ។

វណ្ណៈ យ៉ាងម៉េចបានជាដកចេញ?

សុខខឿនៈ ដូចថាមនុស្សហ្នឹងគេធ្វើសកម្មភាពគេធ្វើអត់បានចឹង គេដកទៅចឹងទៅណាស់ ដល់ពេលរួចគេយកអាថ្មីមកចឹង គេដកអាចាស់ហ្នឹងចេញចូលៗទៅ ។

វណ្ណៈ គេហ្នឹងគេដកយកទៅអប់រំឬគេដកយកទៅសម្លាប់?

សុខឡឿនៈ គេដកយកទៅអប់រំនៅម្តុំព្រៃនប់ កន្លែងកងចល័តធំគេហ្នឹង កន្លែងកងធំគេហ្នឹង ។

វណ្ណៈ ចឹងអ្នកដែលមានសកម្មភាពអន្តការចាប់ខ្លួនយកមកព្រៃនប់?

សុខឡឿនៈ ចាស ។

វណ្ណៈ ចឹងព្រៃនប់និងជាកន្លែងលត់ដំ?

សុខឡឿនៈ ហ្នឹងហើយ ។

វណ្ណៈ មានគុកទេ?

សុខឡឿនៈ កន្លែងនិងមិនមានគុកទេ កន្លែងហ្នឹងគេដាក់អ្នកមានសកម្មភាពដូចថា គេឲ្យយើងទៅស្ទូងទោះ បីយើងឈឺគ្រុនយ៉ាងម៉េចក៏គេឲ្យទៅ ជួនកាលគ្នាទៅងាប់ក្នុងទឹកស្រែអីចឹងណាស់ ។

វណ្ណៈ ម៉េចបានជាមីងដឹង ដឹងតាមណា?

សុខឡឿនៈ ដឹងប្អូនខ្ញុំមកហ្នឹង ពេលមកចឹងវាលួចមកលេងជាមួយយើងចឹងវានិយាយថា ឯងគេឲ្យទៅកងចល័តព្រៃនប់កុំទៅ នៅហ្នឹងនៅទៅកុំទៅកងចល័ត នៅកងចល័តនិងគេធ្វើបាបណាស់ បាយក៏មិនដែលស៊ីឆ្អែតដែរ ហើយទៅចុះស្ទូងទឹកលិចៗខ្លួន ។

វណ្ណៈ ចឹងប្អូនមីងធ្លាប់ធ្វើនៅហ្នឹង?

សុខឡឿនៈ ចាស ។

វណ្ណៈ ប្អូនមីងឈ្មោះអីដែរ ប្អូនបង្កើត?

សុខឡឿនៈ ប្អូនជីដូនមួយ ឈ្មោះ រឿន ។

វណ្ណៈ សព្វថ្ងៃគាត់នៅរស់ទេ?

សុខឡឿនៈ ស្លាប់បាត់ហើយ ។

វណ្ណៈ ស្លាប់នៅពេលណា?

សុខឡឿនៈ ស្លាប់កាលសម័យគេធ្វើបាបហ្នឹង ។

វណ្ណៈ ចឹងស្លាប់នៅព្រៃនប់និងតែម្តង?

សុខឡឿនៈ ចាស ។

វណ្ណៈ ចឹងមីងបានចូលបួរើកងទ័ពហើយមីងស្មោះស្មគ្រដែលហើយមីងនៅខាងស្រុកជាមួយគា មុំក ដែលហេតុអីបានជាគេចាប់ទុកមីងមានសមាសភាពមិនស្អាតល្អ មីងមកកងចល័តលុតដុំអីចឹង ?

សុខខឿនៈ ហ្នឹងដូចជាតាមរយៈមីងហៅឲ្យមកនៅកាត់ដេរស្រែអំបិលហ្នឹងដល់ហើយអាអ្នកវាខូចហ្នឹងវា
មិនយកខ្ញុំមកដាក់កន្លែងខ្ញុំទេ វាមកយកខ្ញុំមកដាក់កងចល័តយកខ្ញុំទៅទុកឃុំមួយខែបានបងខ្ញុំ
រកដំណឹងខ្ញុំនៅកន្លែងកងចល័តហ្នឹងឃើញ ។

វណ្ណៈ បងមីងឃើញឈ្មោះអីដែរ?

សុខខឿនៈ ឈ្មោះទូច ។

វណ្ណៈ បងបង្កើត?

សុខខឿនៈ បងជីដូនមួយបង្កើតហ្នឹង ដល់ហើយគាត់ចេះតែបាត់ខ្ញុំរកអត់ឃើញដើររកខ្ញុំរកអត់ឃើញ
ហើយខ្ញុំគេមិនឲ្យដើរទៅណា ឲ្យនៅតែដល់ម៉ោងវែកដីចេញពីវែកដីហូបបាយពេលសម្រាក
បន្តិចបន្តួចហ្នឹងគេឲ្យសម្រាកនៅក្នុងផ្ទះចេញមកវែកដីតែម្តងអត់មានឲ្យដើរទេ ។

វណ្ណៈ ជាគាត់ប្រធានកាត់ដេរនៅហ្នឹង?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងគាត់ចង់យកមីងមកកន្លែងកាត់ដេរដើម្បីងាយស្រួល?

សុខខឿនៈ ចាស ។

វណ្ណៈ តែមីងមិនបានមកទេ?

សុខខឿនៈ មិនបានមកទេ គេយកខ្ញុំមកទុកនៅកងចល័តហ្នឹងមួយខែ ។

វណ្ណៈ ចឹងមួយខែក្រោយមកបានគាត់រកឃើញ?

សុខខឿនៈ ចាស!រកខ្ញុំឃើញបានខ្ញុំបានចូលមកនៅកន្លែងកាត់ដេរហ្នឹងវិញ ។

វណ្ណៈ ចឹងកន្លែងកាត់ដេរហ្នឹងអត់មានលំបាកទេ?

សុខខឿនៈ កាត់ដេរហ្នឹងអត់លំបាកទេ ។

វណ្ណៈ ចឹងកាត់ដេរតាំងពី៧៧រហូតដល់រត់តែម្តង?

សុខខឿនៈ ចាស!មកនៅកាត់ដេរហ្នឹងស្រួលតែមួយរយៈដែលហ្នឹង ដល់ពេលរកាំកូលគ្នាគេដកបងខ្ញុំបាត់
ទៅមានឈ្មោះយាយ ណនគាត់មកគ្រប់គ្រងហ្នឹងគាត់ដូចរាងសកម្មភាពមិនល្អដែលធ្វើបាប
អ្នកកាត់ដេរហ្នឹងដែលហ្នឹង ។

វណ្ណៈ បងទូចហ្នឹងគេដកគាត់ទៅណា?

សុខខឿនៈ គេដកគាត់ទៅកងចល័ត១គេដកគាត់ទៅបាត់ទៅ ។

វណ្ណៈ មិនដឹងថានៅណាទេរាល់ថ្ងៃ?

សុខខឿនៈ ចាស ។

វណ្ណៈ ប្រហែលជាគេសម្លាប់គាត់ដឹង?

សុខខឿនៈ អត់ទេ ដល់ក្រោយមកឮដំណើរថាគាត់ទៅនៅកំពង់ធំ ពេលដែលគេដកគាត់ហ្នឹងគាត់អត់មានប្រាប់ខ្ញុំថា គេដកគាត់ទៅនៅនេះទៅនៅនោះទេ ដល់ក្រោយមកឮថាគាត់ហ្នឹងទៅនៅកំពង់ធំហ្នឹង ។

វណ្ណៈ ចឹងបាត់រហូតទៅ?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងដល់ពេលចូលឃាយ ណនវិញកាចទេ?

សុខខឿនៈ កាចណាស់ ។

វណ្ណៈ ឃាយ ណនហ្នឹងមកពីខាងណាវិញ?

សុខខឿនៈ ឃាយ ហ្នឹងមិនដឹងនៅស្រុកកំណើតណា ខ្ញុំទើបមកនៅហ្នឹងពេលយើងដាំដំឡូងដាំអីទៅវាជ្រូកព្រៃវាមិនមកស៊ី ។

វណ្ណៈ បាទ ។

សុខខឿនៈ ចឹងចាត់ចែកពួកខ្ញុំកំលាំងចេញពីទ័ពមកនៅហ្នឹងមាន៣៥នាក់ឲ្យទៅយាមដំឡូងជ្រូកហ្នឹងដល់ពេលយាមវាអត់ឈ្នះវាស៊ីដល់ពេលគេទៅពិនិត្យតាមដានទៅវាឃើញជ្រូកស៊ីដំឡូងទៅគេថាគេប្រើឲ្យមកយាមជ្រូកម៉េចបានឲ្យជ្រូកចូលស៊ីដំឡូង ដល់យើងខ្ញុំឆ្លើយថាអ៊ឹងចេះតែនិយាយបើព្រៃប៉ុណ្ណណឹមនុស្សពីរបីនាក់ទៅយាមជ្រូកយ៉ាងម៉េចឈ្នះ វាចូលមកវាចូលបានបាត់ហើយយើងយាមយ៉ាងម៉េចឈ្នះ យប់នាំគ្នាដេកហើយវាចូលមកយើងម៉េចដឹង ដល់ព្រលឹមឡើងដើរលុកមកបានឃើញវាស៊ីគេថាយើងហ្នឹងសកម្មភាពមិនល្អ អីចឹង ។

វណ្ណៈ តាមពិតជ្រូកស៊ីសោះ?

សុខខឿនៈ ចាស! ជ្រូកឈ្លូសហើយយកយើងមកដុតស៊ីអាក្បាលៗហ្នឹង ដុតស៊ីគេថាឲ្យយើងទៀតគេមិនឲ្យយើងយកមកហូបទេ ។

វណ្ណៈ ចឹង?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងនៅពេលជ្រូកស៊ីចឹង គេធ្វើយ៉ាងម៉េចទៅមឹងអ្នកយាមប៉ុន្មាននាក់ហ្នឹង?

សុខខឿនៈ ពេលចឹងគេឈប់ឲ្យយើងទៅយាម ឈប់ឲ្យយើងទៅយាមថា យើងហ្នឹងសកម្មភាពមិនល្អទេគេឈប់ឲ្យទៅយាមជ្រូក យាមនៅឲ្យជ្រូកចូលស៊ីដំឡូងក៏ពួកខ្ញុំហ្នឹងឈប់ទៅ ។

វណ្ណៈ ចឹងគេអត់យកទៅណាសកម្មភាពអីទេ?

សុខខឿនៈ អត់ផង តែគេនៅតាមដានយើង ។

វណ្ណៈ ចឹងតាមដានយើងទៀត?

សុខខឿនៈ ចាស ។

វណ្ណៈ តែគេដឹងថាជ្រូកមែនដែរ?

សុខខឿនៈ ចាស!ដឹងថាជ្រូកហើយយើងម្តងចឹងចុះដូចខ្ញុំដូចថាអត់សូវនេះចឹង ដំឡូងជ្រូកឈ្មួសចឹងសល់ចឹងយើងយកមកដុតចឹង គេមកឃើញយើងដុតដំឡូងស៊ីហ្នឹងគេថាយើង ។

វណ្ណៈ ចឹងមីងនៅហ្នឹងរហូតដល់រត់៧៩តែម្តង?

សុខខឿនៈ ចាស!ខ្ញុំនៅកាត់ដេរហ្នឹងរហូត ។

វណ្ណៈ ចឹងមីងកាលហ្នឹងអត់មានឋានៈអីទេ?

សុខខឿនៈ ខ្ញុំអត់ ។

វណ្ណៈ ចឹងនៅកម្មករ?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងគេអត់មានបញ្ជូនមីងទៅខេត្តណាផ្សេងទៀតទេ?

សុខខឿនៈ គេបញ្ជូនកងខ្ញុំបំបែកពីកងទ័ពចេញពីកាត់ដេរហ្នឹងដកបង១ទៅនៅកងចល័តទៅ ខ្ញុំតវ៉ាថាមិនឲ្យដកថាតែដកបង១ហ្នឹងទៅទៀតគេធ្វើបាបយើងចឹង ពួកខ្ញុំថាគាត់ខុសអីដកគាត់ទៅនៅកងចល័តខ្ញុំតវ៉ាចឹង ។

វណ្ណៈ តវ៉ាឲ្យពីណាគេ?

សុខខឿនៈ តវ៉ាឲ្យបង១រំលាយពីទ័ពមកកាត់ដេរហ្នឹងទាំងអស់គ្នាហ្នឹង ។

វណ្ណៈ បាទ ។

សុខខឿនៈ តែគាត់ហ្នឹងជាចាស់ទុំគ្រប់គ្រងយើងអ្នកមកកងជាមួយគ្នាចឹង គេដកបង១បីបួននាក់ហ្នឹងទៅនៅកងចល័តពួកខ្ញុំមិនឲ្យទៅ ។

វណ្ណៈ ចឹងមិនឲ្យទៅនៅហ្នឹងទាំងអស់គ្នាទៅ?

សុខខឿនៈ អត់ឲ្យទៅដល់ហើយគេប្រជុំចឹងពួកខ្ញុំ តវ៉ាថាគាត់ខុសអីបានជាដកគាត់ទៅនៅកងចល័ត បើខុសអីខុសអីបងឯងនិយាយទៅ អ្នកនេះខុសបេះខុសចុះទៅ អាចដកទៅនៅកងចល័តអីទៅវាអស់ចិត្តហើយ ស្ងាត់១គ្នាអត់មានខុសអីផងដកគ្នាទៅនៅកងចល័ត ។

វណ្ណៈ ចឹងកាលហ្នឹងមីងហ៊ានតវ៉ាចឹង?

សុខខឿនៈ ហ៊ានតើ ។

វណ្ណៈ តា វ៉ាជាមួយយាយ ណនហ្នឹង?

សុខខឿនៈ ហ្នឹងហើយ តវ៉ាជាមួយយាយ ណនហ្នឹង ។

វណ្ណៈ ហើយយាយ ណនថាយ៉ាងម៉េចទៅ?

សុខខឿនៈ យាយ ណនថា ពួកផែ៎ងមានដឹងអីខុសស្អីក៏ផែ៎ងអត់ដឹងដែរ ខ្ញុំថាចុះគាត់នៅតែដេរទាំងអស់គ្នាហ្នឹងគាត់មានធ្វើអីខុសផងហ្នឹង ។ ហើយមីងឯងយកគាត់ទៅដាក់នៅកងចល័តគាត់នៅគ្រប់គ្រងខ្ញុំប៉ុណ្ណឹងហើយអ៊ឹងឯងធ្វើបាបខ្ញុំប៉ុណ្ណឹង ។ ចុះបើគាត់ទៅទៀតអ៊ឹងឯងធ្វើបាបខ្ញុំយ៉ាងម៉េចទៅនាំគ្នាថាចឹង ដល់ហើយពេលស្លាត់ៗលួចដកពួកហ្នឹងទៅអស់ ។ លួចដកទៅទាល់តែបានលួចដកបងៗហ្នឹង ។

វណ្ណៈ៖ ចឹងមីងនៅជាមួយគាត់ទៀតទៅ?

សុខខឿនៈ ចាសខ្ញុំនៅជាមួយយាយ ណនហ្នឹងរហូតដល់ពេលហើយមិនពួកខ្ញុំហ្នឹងបងៗនិយាយចឹងបងៗគាត់ទៅបាត់ចឹងឡានគេមកយកគាត់ហ្នឹង ឡានកង់តានើមួយធំនៅហ្នឹងគ្នាខ្ញុំ៣៦នាក់ហ្នឹងកំពង់តែដេរហ្នឹងនាំគ្នារត់ឡើងឡានទាំងអស់រត់តាមគាត់ហ្នឹង ។

វណ្ណៈ៖ ចឹងយ៉ាងម៉េចទៅ?

សុខខឿនៈ ដល់ពេលរត់តាមគាត់និងទៅយាយ ណនហៅទ័ពស្រុកហ្នឹងមកចាប់ពួកខ្ញុំ តែពួកខ្ញុំកាលហ្នឹងនៅមានកាំភ្លើងគ្រប់ដៃ ពេលហ្នឹងគេដកមកពួកខ្ញុំក៏មកវិញឈរនៅផ្ទះហ្នឹង គេដកកាំភ្លើងដកអីអស់ហើយ ខ្ញុំថាដកៗទៅកាំភ្លើងមានធ្វើអី ទោះអ៊ឹងឯងថាពួកខ្ញុំក្បត់ក៏ថាបានដែរ ។ បើខ្ញុំយាមជ្រូកប៉ុណ្ណឹងថាខ្ញុំយាមមិនឈ្នះជ្រូក អ្នកណាយាមជ្រូកឈ្នះនោះជ្រូកព្រៃ ។

វណ្ណៈ៖ កាលហ្នឹងជ្រូកច្រើនសត្វច្រើនសម្បូរ?

សុខខឿនៈ ចាស!ដល់ពេលរួចគាត់ធ្វើសំនើរទៅលើទៀតថា ពួកខ្ញុំក្បត់លួចរត់តាមគ្នាទៅណា ទៅកងចល័តអីណា ដកចឹងគេដកពួកខ្ញុំឈប់ឲ្យដេរដល់ហើយគណៈតំបន់នៅព្រៃនប់ហ្នឹងមកប្រជុំមកដោះស្រាយ ។

វណ្ណៈ៖ ចឹងមីងមានស្គាល់គណៈតំបន់ហ្នឹងទេ?

សុខខឿនៈ ឈ្មោះតា អីខ្ញុំភ្លេចឈ្មោះបាត់ហើយ ។

វណ្ណៈ៖ ព្រៃនប់ហ្នឹងនៅតំបន់ប៉ុន្មានមីងមានដឹងទេ?

សុខខឿនៈ ព្រៃនប់ហ្នឹងតំបន់ប៉ុន្មាន មីងដូចជាអត់សូវចាប់អារម្មណ៍ដែរ ។

វណ្ណៈ៖ ចឹងភូមិភាគអីមីងមានដឹងទេ?

សុខខឿនៈ ភូមិភាគអីទេ ។

វណ្ណៈ៖ ចឹងគេឲ្យមីងបន្តនៅដេរហ្នឹងដដែលឬមួយគេឲ្យមីងទៅណា?

សុខខឿនៈ គេឲ្យនៅកាត់ដេរហ្នឹងរហូតទាល់តែរត់៧៩ហ្នឹងតែម្តង ។

វណ្ណៈ៖ យាយ ណនហ្នឹងក៏នៅហ្នឹងដែរ?

សុខខឿនៈ យាយ ណនក៏នៅហ្នឹង តែក្រោយមកគេចាប់គាត់បានពីរថ្ងៃយើងរត់ហ្នឹងតែម្តង ។

វណ្ណៈ ចឹងយាយ ណាទេគេចាប់ដែរ?

សុខខឿនៈ ចាស!គេចាប់ គេដកគាត់យកទៅបាត់ ចាប់ហើយកាលហ្នឹងគេមិននិយាយថាចាប់និយាយថាដក កូនឡានសម្រាប់ដឹកមនុស្សចូលមកកន្លែងហ្នឹង មកកន្លែងផ្ទះហ្នឹង ។

វណ្ណៈ គាត់អ្នកនៅខាងណាយាយ ណាទហ្នឹង?

សុខខឿនៈ យាយហ្នឹងមិនដឹងជាស្រុកណា យាយហ្នឹងនៅកំពតឬនៅណាទេនេះ ។

វណ្ណៈ ចឹងភាគច្រើនឲ្យតែឃើញកូនឡានចូលទៅចឹងដឹងថាចាប់ហើយ?

សុខខឿនៈ អាឡានអាស្រ៊ីបហ្នឹងឲ្យតែចូលទៅកន្លែងណាដឹងថាយកមនុស្សកន្លែងហ្នឹងតែម្តង ឡានអាស្រ៊ីបចាប់មនុស្សហ្នឹង ។

វណ្ណៈ ស្គាល់ចឹងតែម្តង?

សុខខឿនៈ ចាស!ឲ្យតែឃើញកូនឡានឃើញកូនឡានចេញទៅចឹងមកវិញដឹងថា ។

វណ្ណៈ ចឹងមីងនៅកន្លែងកាត់ដេរហ្នឹងមីងហូបចុកគ្រប់គ្រាន់ដែលទេ?

សុខខឿនៈ ហូបចុកអត់អីទេ ។

វណ្ណៈ ចឹងមីងមានដឹងប្រជាជននៅជាយៗហ្នឹងនៅតាមសហករណ៍អីហូបចុកយ៉ាងម៉េចដែរ?

សុខខឿនៈ នៅតាមហ្នឹងហូបវេទនាដែលហ្នឹង បាយសម្លឲ្យគ្នាស្លតែប្រលិត ស្លតែប្រាច់មានម្ហូបអីហូប ។

វណ្ណៈ ចឹងទោះបីមានត្រីច្រើនក៏គេមិនឲ្យហូបច្រើនដែរ?

សុខខឿនៈ ចាស!មានត្រីច្រើនយ៉ាងម៉េចក៏គេមិនឲ្យហូបដែរ ។

វណ្ណៈ ចឹងមីងពេលវៀតណាមចូលមកនៅឆ្នាំ៧៩ យ៉ាងម៉េចបានជាមីងមិនរត់មករកស្រុកកំណើតកាលហ្នឹង?

សុខខឿនៈ រកផ្លូវរត់មកមិនឃើញ ចេះតែរត់តាមព្រៃតាមផ្លែរតាមទ័ពមកចឹងរហូត ម្យ៉ាងខ្លាចយួនចាប់ដងរត់តាមស្រុកចេះតែរត់តាមព្រៃទៅ ។

វណ្ណៈ មីងខ្លាចយួនដែរ?

សុខខឿនៈ ខ្លាច ។

វណ្ណៈ មីងរត់មកតាមផ្លូវហ្នឹងមីងជួបការលំបាកយ៉ាងណាខ្លះ ហើយមានឃើញមនុស្សស្លាប់តាមផ្លូវជាយដែនយ៉ាងម៉េចមីងមានដែលជួបប្រទះទេ?

សុខខឿនៈ វេទនាណាស់ រត់ចូលព្រៃនោះ តើរត់រាប់ខែរាប់ឆ្នាំមិនដែលមានអីហូប យើងហូបតែគបឈើគបស្មៅគបអីគបអីដែលយើងហូបបានចេះតែហូបទៅអត់ទាំងអំបិលអត់ទាំងអី ។

វណ្ណៈ ដែលហូបស្លឹកឈើទេ?

សុខខឿន៖ ហូបអាស្អីកខៀវៗឲ្យតែគេថាហូប ហូបស្អីកម្កាក់អីហ្នឹងដូៗហ្នឹងយើងចេះតែហូបទៅគល់ចេក គល់អីហ្នឹង ។

វណ្ណៈ ចុះយើងមិនរត់ក្បែរៗភូមិទៅមានម្ហូបមានអាហារខ្វះ?

សុខខឿន៖ ចុះយើងស្រីៗដឹងធ្វើម៉េចបានដូចជាគោក្របីលែងក្នុងព្រៃយើងធ្វើអត់បានហូបទេ យើងអត់ហ៊ាន អត់ហ៊ានបាញ់វាធំៗចឹង ។

វណ្ណៈ ចឹងជួបដែលតែយើងអត់ហ៊ាន?

សុខខឿន៖ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងមានស្លាប់ទេ ពេលរត់ពេលអីហ្នឹង?

សុខខឿន៖ មានស្លាប់តែយើងមិនស្គាល់មនុស្សណាស់ ជួនកាលយើងដើរជីកដំឡូងអីចឹងឃើញស្លាប់តាមថ្នល់តាមផ្លូវព្រៃអីចឹងទៅ ។

វណ្ណៈ ចឹងមីងមានភ័យទេ ឃើញមនុស្សស្លាប់តាមព្រៃអីចឹង?

សុខខឿន៖ ភ័យខ្លាចចុះពេលខ្លាចខ្មោចដល់ពេលចឹងទៅលែងខ្លាចអីចង់ទៅជីកដំឡូងអីលែងខ្លាចទៅតែឯង ចេះតែទៅហើយជួនកាលទៅចឹងអត់មានមនុស្សស្លាប់ទេ ស្រាប់តែមកវិញឃើញមនុស្សស្លាប់តាមផ្លូវ ។

វណ្ណៈ ចុះមានអ្នករត់មកបន្តបន្ទាប់គ្នាទៀត?

សុខខឿន៖ ចាស!មកបន្តបន្ទាប់ ។

វណ្ណៈ និយាយចឹងពេលរត់វៀតណាមចូលហ្នឹងមានសាប់មនុស្សច្រើនទៀត?

សុខខឿន៖ មានសាប់ច្រើនទៀត មានសាប់ច្រើនណាស់ មិនបងគេមិនថាម៉ែគេ មិនថាប្អូនគេទេ ។

វណ្ណៈ ចឹងនៅពេលឃើញមនុស្សច្រើនចឹងមីងកាន់តែនឹកផ្ទះដែលឬមួយយ៉ាងម៉េច?

សុខខឿន៖ នឹកណាស់ រត់ស្វែងរកតែបងប្អូនប្អូនម៉ែឪដែលតែមិនបានជួប អ្នកស្រុកភូមិក៏អត់មានជួប មីងរត់មកនៅម្តុំថ្មបាំងថ្មីអីនេះ ។

វណ្ណៈ ចឹងនៅពេលដល់ព្រំដែនមីងមានបានជួបជុំគ្នាបង្កើតជាកងដឹកជញ្ជូនមានកាកបាទគេចូលមក ឆ្នាំណាមីងមកដល់ព្រំដែនបានទទួលម្ហូបអាហារឡើងវិញ?

សុខខឿន៖ មកដល់៨០-៨១ហើយ ។

វណ្ណៈ ចឹង៨០-៨១ហើយ?

សុខខឿន៖ ចាស ។

វណ្ណៈ ចឹង៨០-៨១ហ្នឹងមីងរត់មកដល់ណា?

សុខខឿន៖ មកដល់ថ្មដាយើងនេះ ។

វណ្ណៈ ថ្ងៃជាហ្នឹងនៅជាប់ថៃ?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងមីងអត់មានទៅខាងម៉ាឡៃទេ?

សុខខឿនៈ អត់ផង ។

វណ្ណៈ សំឡូត ម៉ាឡៃ?

សុខខឿនៈ អត់ ។

វណ្ណៈ អន្លង់វែងអីអត់មានទៅខាងហ្នឹងទេ?

សុខខឿនៈ អត់ ។

វណ្ណៈ ទៅថ្ងៃជាដល់ពេលណាទៅ?

សុខខឿនៈ នៅថ្ងៃជារហូត នៅថ្ងៃជាដល់ពេលរួចមីងហ្នឹងមកនៅកងដឹកជញ្ជូនវិញ ។

វណ្ណៈ ចឹងពេលហ្នឹងមីងចូលកងដឹកជញ្ជូនហើយ?

សុខខឿនៈ ចាស ។

វណ្ណៈ មីងមានគ្រួសារនៅពេលហ្នឹង?

សុខខឿនៈ មីងនៅឆ្នាំ៨៥នេះហើយ ទើបមានដែលហ្នឹង ។

វណ្ណៈ ចឹងមីងនៅដឹកជញ្ជូនមានគ្រាប់មានអង្ករអីហ្នឹង?

សុខខឿនៈ មានគ្រាប់មានថ្នាំពេទ្យមានអង្ករ ។

វណ្ណៈ យកទៅឲ្យយុវជនទៅវៃជាមួយត័ពវៀតណាម?

សុខខឿនៈ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងស្រីៗគេមានឲ្យកាន់កាំភ្លើងឡើងវៃដែរ?

សុខខឿនៈ កាលពីមុនកាន់កាំភ្លើងតើ តែក្រោយមកមានដឹកជញ្ជូនចឹងបានគេឈប់ឲ្យកាន់កាំភ្លើង គេឲ្យស្រីៗដឹកជញ្ជូនវិញ ។

វណ្ណៈ ចឹងប្រុសៗឡើងវៃ?

សុខខឿនៈ ចាស ។

វណ្ណៈ មីងមានភ័យទេពេលឡើងវៃជាមួយវៀតណាមមួយសាទៀត?

សុខខឿនៈ ភ័យតើ ប៉ុន្តែយើងមិនដែលវៃទេ តែយកគ្រាប់ទៅដូចជាយើងទៅវៃទល់មុខគ្នាដែលហ្នឹងឧទាហរណ៍ថា យើងជញ្ជូនគ្រាប់ចឹងទៅយួនវាអត់ទាន់មកទេណា ពេលយើងទៅហួសមួយម៉ោងពីរម៉ោងពេលយើងត្រឡប់មកវិញ គេព័ទ្ធពីក្រោយជាប់ហើយ ។ ចឹងយើងនៅទល់មុខជា

មួយទ័ពនៅនឹងមុខនឹងដូចតែគ្នានឹង ។ ទាល់តែវៃបើកផ្លូវបើកអីបាន បានយើងចេញមករួចចឹងទៅ ។

វណ្ណៈ៖ ដូនកាលយើងដើរចូលទៅអត់ទាន់មកទេ?

សុខខឿនៈ ចា៎!

វណ្ណៈ៖ ដល់មកវិញ ឃើញ?

សុខខឿនៈ វាស្អាត់យើងបាត់ ។

វណ្ណៈ៖ យើងឃើញអត់ហ៊ានមកទៀតទេ?

សុខខឿនៈ យើងអត់ហ៊ាន ។

វណ្ណៈ៖ ចឹងកាលនឹងនៅថ្មបាំង ថ្មអី ប្រធាននៅកងពលពីណាគេ?

សុខខឿនៈ កាលនឹងអត់មានកងពលកងអីផង មនុស្សរតាតរតាយនៅលែងមានអគ្គភាពបាត់ ។

វណ្ណៈ៖ ចុះដល់ក្រោយៗទៀតនោះ?

សុខខឿនៈ ដល់ពេលក្រោយៗមក យើងដើរៗនៅ ឧទាហរណ៍ថាគេចង់ប្រមូលមនុស្សឡើងមកព្រំដែនចឹង គេដើមប្រមូលមនុស្សចឹង ។ ថាម៉ាកន្លែងនឹងមានមនុស្សប៉ុន្មាននាក់ កន្លែងនោះមានមនុស្សប៉ុន្មាននាក់ ។ ចឹងខាងអគ្គការនឹង គេឲ្យប្រមូលមនុស្សឡើងទៅព្រំដែន ។ ចឹងចេះដើរប្រមូលគ្នាមកទ័ពពីព្រំដែនឡើងទៅប្រមូល ។ ដល់ប្រមូលបានគ្នា៥០-៦០នាក់ ឡើងមកម៉ាសារចឹងទៅ ។ ហើយអ្នកពីនេះទៅគេបញ្ជូនអគ្គរដាក់ស្រាក់ៗ សម្រាប់ឲ្យយើងឡើងពីនឹងទៅ ហូបតាមផ្លូវអីចឹង ។

វណ្ណៈ៖ តែក្រោយមកទៀត ឆ្នាំ៨០ជាងអាចមានជាងកងពល កងអីហើយខាងនឹង?

សុខខឿនៈ មាន ។

វណ្ណៈ៖ ពីណាគ្រប់គ្រងថ្មដា បើនៅខាងសំឡូតដូចតាហុង តាកន តាអីចឹង?

សុខខឿនៈ នៅនោះតាសេង នៅកោះកុង ។

វណ្ណៈ៖ ថ្មដានឹង?

សុខខឿនៈ ចា៎! តាសេង តាអ៊ឹម ។

វណ្ណៈ៖ អានឹងគាត់ឆ្នាំ៨០ជាង គាត់ដឹកនាំ?

សុខខឿនៈ ចា៎! អានឹង៨០ជាង ។

វណ្ណៈ៖ តាសេង តាអ៊ឹម សព្វថ្ងៃគាត់នៅទេ?

សុខខឿនៈ គាត់ស្លាប់អស់ហើយ ។ តាអ៊ឹមដូចនៅ តាសេងស្លាប់ហើយ ។

វណ្ណៈ៖ ស្លាប់មូលហេតុអី?

សុខខឿនៈ ស្លាប់ឈឺ ។ ប៉ុនគាត់ដូចនៅ ។

វណ្ណៈ ចុះក្រោយៗមកទៀត មានពីណាទៀត?

សុខខឿនៈ ក្រោយៗមកទៀត ដឹង មានគេទៀត ។ ប៉ុនខ្ញុំបែកពីនឹងមកហើយនឹង បែកមកនៅជាមួយអង្គភាពតាបូរាណវិញ ។

វណ្ណៈ តាបូរាណវិញ?

សុខខឿនៈ ចាំ!

វណ្ណៈ តាបូរាណ ប្រធានកងពលប៉ុន្មាន?

សុខខឿនៈ គាត់ប្រធានដឹកជញ្ជូន ហ្នឹងអត់មានកងពលផង គាត់ដឹកជញ្ជូន មកកន្លែងខាងនិរតីនេះ ។

វណ្ណៈ តាបូរាណនឹងប្រធានដឹកជញ្ជូន?

សុខខឿនៈ ចាំ!

វណ្ណៈ ចុះតាវ៉ែន តាអី?

សុខខឿនៈ តាវ៉ែន នឹងគេ គាត់ខាងទ័ព ។

វណ្ណៈ ទ័ពគាត់កាន់នៅខាងនឹងដែរ ថ្មបាំងនឹង?

សុខខឿនៈ អត់ទេ ខាងផ្ទះមួយ ផ្ទះអី អូរទី១ហ្នឹងហើយ ។

វណ្ណៈ ចុះតាសេង តាអ៊ុមនឹង កងពលទីប៉ុន្មាន?

សុខខឿនៈ កងពលទី៣ ។ ហ្នឹងទ័ពគេ បើដឹកជញ្ជូនដូចអត់មាន ។

វណ្ណៈ តាវ៉ែនកងពលទី១?

សុខខឿនៈ ចាំ!

វណ្ណៈ ប៉ុន្តែគាត់នៅខាងកោះកុងដែរ?

សុខខឿនៈ ចាំ! គាត់នៅនឹង ។ មនុស្សធ្វើគំនិតល្អ ដល់ពេលស្លាប់ទៅវេទនាណាស់ ។

វណ្ណៈ ម៉េចចឹង?

សុខខឿនៈ ដូចតាវ៉ែននឹង គាត់ធ្វើបាបប្រជាជន គាត់ធ្វើបាបចិត្តគេខ្លាំង ដល់ពេលគាត់ស្លាប់ទៅវេទនាណាស់ ។

វណ្ណៈ តាវ៉ែននឹង គាត់ធ្វើបាបប្រជាជនពេលណាមក?

សុខខឿនៈ កាល៨០ ៨១នឹង គាត់ដាក់កាំភ្លើងដើរបាញ់តាមភូមិ តាមអី បាញ់មាន់ បាញ់ទា ប្រជាជនបណ្តោយ ។

វណ្ណៈ ចឹងមីងជឿថាកម្មពៀរមានមែន?

សុខខឿនៈ ខ្ញុំជឿ ។ តាវ៉ែននឹងស្រីក៏ស្រី ចាប់ស្រីយកទៅខ្លាំងនឹងតានោះ ។

វណ្ណៈ អត់ខ្លាចតាម៉ុកទេ?

សុខខឿនៈ គាត់អត់ខ្លាចទេ កាលនឹងគាត់នៅមុខផ្លូវម្តុំថ្មដាររនេះផ្ទះមួយ ។

វណ្ណៈ ក្រែងគាត់កូនប្រសារតាម៉ុក គាត់មានប្រពន្ធ?

សុខខឿនៈ គាត់កូនប្រសារមានប្រពន្ធ តែប្រពន្ធទុកដោយឡែក ហើយគាត់នឹងអាងតែមេទ័ពអាងមេទាហានចឹង ស្រីគាត់ធ្វើផ្ទះគាត់ចូលឲ្យជ្រៅ គាត់ឲ្យនិរសាដើររាស ស្រីណាដឹកជញ្ជូនស្អាតៗយកទៅឲ្យគាត់អស់ហើយ ។ ចឹងបានថាគំនិតគាត់ ថាមនុស្សស្រីៗស្អាតៗសម្រាប់តាវ៉ែនហ្នឹងទេ នឹងសំណាងអ្នកដឹកជញ្ជូនពីមុន ។ ដល់ពេលគាត់ស្លាប់ទៅ គាត់វេទនាណាស់ មុននឹងស្លាប់នឹងរាប់ខែ គាត់ស្រែកៗម៉ាយប់ៗគ្មានអ្នកណាបានដេកទេ ។ ពួកខ្ញុំមិនដែលទៅមើលគាត់ឈឺ និរសាគាត់ហៅឲ្យទៅ ខ្ញុំមិនទៅទេ ។

វណ្ណៈ ចឹងបើគេស្រីៗដឹកជញ្ជូនស្អាតៗ បើគាត់ស្រឡាញ់អត់រួចខ្លួនទេចឹង?

សុខខឿនៈ អត់រួចខ្លួនទេ ដឹងបានគាត់នឹងម៉ង ។

វណ្ណៈ ចុះមានអ្នកណាសម្លាប់ខ្លួនដោយសារគាត់ ដូចថាគាត់ធ្វើបាប ស្លាប់ខ្លួន?

សុខខឿនៈ មានតើប្អូន ។

វណ្ណៈ នៅណា? ដូចថាគាត់ធ្វើបាបអីចឹងទៅ ក៏តូចចិត្តតូចអីស្លាប់ មានដែរ?

សុខខឿនៈ មានតើ ។

វណ្ណៈ ប៉ុនមីងអីអត់អីទេ រួចខ្លួន?

សុខខឿនៈ ខ្ញុំអត់អីទេ

វណ្ណៈ ហើយគេថាតាវ៉ែននឹង បាញ់សត្វព្រៃសត្វអីណា?

សុខខឿនៈ ហ៊ើ! អានឹងតាបូរាណទេ ។

វណ្ណៈ តាណាថាចេះហៅសត្វហៅអីទៀត តាបូរាណនឹងមែន?

សុខខឿនៈ តាបូរាណ ។

វណ្ណៈ គាត់ចេះហៅសត្វម៉េច?

សុខខឿនៈ គាត់ចេះអីម៉េច ប៉ុន្តែគាត់ត្រៀមសត្វមកដូចថាគាត់ដឹកជញ្ជូនចឹង ក្នុងម៉ាដើង មុននឹងគាត់ពេលសម្រាក គាត់ថាពួកយើងចង់ស៊ីសត្វអី ចង់ស៊ីជ្រូក ស៊ីប្រើស ហើយចង់ខ្ទីញ គាត់ថាចឹង ។ ដល់ហើយពួកនឹងថា គ្នាដូចច្រើនណាស់ ដាក់ដីរមួយទៅ គាត់ទៅហើយ គាត់ទៅម៉ោង៧ម៉ោង ព្រូសូរកាំភ្លើង ម៉ាសន្ទុះគាត់មកវិញ គាត់ឲ្យទៅវះសាច់ហើយ ។

វណ្ណៈ ចឹងគាត់អ្នកបាញ់ផ្ទាល់?

សុខខឿនៈ ចា៎! គាត់អ្នកបាញ់ផ្ទាល់ខ្លួនឯង ។

វណ្ណៈ ចង់ហូបសត្វអី បានសត្វនឹង?

សុខខឿនៈ ចាំ!

វណ្ណៈ តែក្រោយមកគាត់ស្លាប់ដែរ?

សុខខឿនៈ ក្រោយមកគាត់ស្លាប់ៗមុននឹងស្លាប់នឹង គាត់ទៅបាញ់សត្វ ហើយកាលនឹងទាហានឡើង ដឹង ទាហានដែរតើ ទៅនឹងឲ្យប្រុងប្រយ័ត្នផង អ្នកកងការពារនឹង។ ដល់ថ្ងៃនឹង គាត់គាបាញ់ដឺរី នឹង ដឺរីនឹងផាប់អស់ម៉ាគូ។ គាត់បាញ់ដឺរី បើគាត់ចំឡែកបាញ់ដឺរីអត់ដួលចឹងទេ។ នេះដឺរី បាញ់ទាំង២ផាប់ លុតជង្គង់ ហើយយកអាប្រមោយវានឹងបុកដីចឹង បាញ់មួយទៀតក៏ចឹង ទៀត លុតជង្គង់ក្រឹប យកអាប្រមោយវាបុកដី ហើយបានដួលចេះ។ គាត់ដើរមកវិញ គាត់និយាយថា អឺ!ហាំ! អញបាញ់សត្វម៉ាសារនេះដូចរៀងម៉េច ដូចរៀងមិនស្រួលសោះ មានកើតហេតុអីមួយ។ ដល់ថ្ងៃនឹង ដេកឆ្ងល់សត្វនឹងឡើង២ថ្ងៃ។ ហើយទាហានយួនវា ត្រៀមផ្លូវ ទាហានវាឡើងវាត្រៀមផ្លូវយើងដើរនឹង។ ដល់ពេលហើយ គាត់ថាចឹង ព្រលឹមឡើងគាត់ហៅពួកកងពិសេសដើរ។ ចុះកាលនឹងមិនរៀបចំពួកពិសេស ពួកអី ការពារអ្នកដឹកជញ្ជូននោះពូ។ ចឹងហៅមកថា ហែំងម៉ាក្រុមដើរដាច់១០០ម៉ែត្រ១ ពី កម្លាំងធំចឹងទៅ ហើយក្រុមការពារក្រោយការពារឲ្យឆ្ងាយពីកម្លាំងធំ។ ចឹងដល់ពេលទាហាន អាយួននឹង អាកងការពារទៅមុខវាមានបាញ់អី វាឲ្យរួចខ្លួនចឹង។ វាដឹងហើយ ចាំបាញ់ កម្លាំងធំ។ ដល់ពេលផ្លូវ២ ផ្លូវទី១ យួនត្រៀមនេះ ផ្លូវទី២ វាអត់ត្រៀមទេ ដល់ពេលអា ផ្លូវវាអត់ទៅៗផ្លូវទី២នេះ។ ដល់ពេលកម្លាំងវាដើរបែកខ្វែកគ្នា២ ម៉ាខ្សែទៅនេះៗ ដល់ ពេលគាត់នាំកម្លាំងខ្សែទី២ទៅចេះ គាត់នាំទៅមុខគេ យួនបាញ់ស្លាប់នៅនឹង។

វណ្ណៈ ចុះស្លាប់ប៉ុន្មាននាក់ យួនបាញ់?

សុខខឿនៈ ស្លាប់៣នាក់។

វណ្ណៈ ឆ្នាំណាដែរស្លាប់?

សុខខឿនៈ ៨០ហើយ។

វណ្ណៈ ហាំ! ឆ្នាំ?

សុខខឿនៈ ឆ្នាំ៨០ប៉ុន្មាន បងបូរាណស្លាប់។

វណ្ណៈ មីងការនៅ មិនទាន់ការទេ?

សុខខឿនៈ ខ្ញុំមិនទាន់ការផង។

វណ្ណៈ ចឹង៧៩ បានម៉ាឆ្នាំ។ ចុះ៨០អី ៨១ ៨២អីយ៉ាងម៉េច?

សុខខឿនៈ អាច៨៣ គាត់ស្លាប់នឹងនោះ។

វណ្ណៈ	អាយុខ្ទីដែរ?

សុខខឿនៈ គាត់បាញ់សត្វច្រើនពេក ។

វណ្ណៈ	ចឹងអានឹងក៏កម្មពៀរដែរ?

សុខខឿនៈ ចា៎! អានឹងក៏កម្មពៀរ សម្លាប់គេ ។

វណ្ណៈ	គាត់នៅក្មេងដែរ?

សុខខឿនៈ គាត់នៅក្មេងជាងគាត់(វណ្ណៈ)ទៀត ។ ប៉ុនគាត់ដោះស្រាយដំណាំ គាត់ដោះស្រាយធូរណាស់ គាត់អត់មាន ។

វណ្ណៈ	បើតាវ៉ែនអានឹងបានគាត់សាហាវម៉ង?

សុខខឿនៈ ចា៎! តាវ៉ែន គាត់សាហាវ ។

វណ្ណៈ	ឲ្យតែស្រីៗ គឺអត់រួចពីគាត់?

សុខខឿនៈ អត់រួចទេ ។

វណ្ណៈ	ដល់ពេលគាត់ស្លាប់ ឈឺម៉េចរវើរវាយម៉េច?

សុខខឿនៈ តាវ៉ែនៗ គាត់មុននឹងនេះ គាត់ទៅចូលយកពងពស់ ពងអីនៅដីថៃទៀត ។

វណ្ណៈ	ពងពស់អី?

សុខខឿនៈ ពងពស់នៅរូង ។

វណ្ណៈ	ពស់វែក?

សុខខឿនៈ ចា៎! នៅរូងវត្តនឹង ដល់ហើយតាវ៉ែននឹងបញ្ជានិរសាឲ្យទៅយក ដល់ពេលនិរសាអត់ហ៊ានទៅយក គាត់បវឡានចូលទៅយកខ្លួនឯងម៉ង ពងពស់ ។ ពេលចូលទៅយកចឹង គ្រាន់តែយកពស់នឹងមកស្ងោរហូបហើយ គាត់ចាប់ផ្ដើមឈឺពោះទៀត ។

វណ្ណៈ	បាញ់ពស់បានទៀត?

សុខខឿនៈ អត់ទេ ពស់នឹងហើយ បាញ់មេនឹង ពស់កំពុងក្រាបពងបាញ់មេនឹងងាប់ទៀត ។

វណ្ណៈ	ធំទេ ពស់នឹង?

សុខខឿនៈ ពស់នឹងធំ ឡើងជិតប៉ុនភ្លៅហើយ ។ យកទាំងមេ យកទាំងពង យកមកស្ងោរហូបៗហើយ ចាប់ផ្ដើមឈឺរហូត ។

វណ្ណៈ	ពស់នៅក្នុងវត្តដីថៃ?

សុខខឿនៈ ចា៎ៗ នៅវត្តដីថៃ គេហៅវត្តស្តីភ្លេច ។

វណ្ណៈ	មិនមែនពស់នៅព្រៃ?

សុខខឿនៈ អត់ទេ វានៅរូងនៅនឹងវត្តនឹងម៉ង ។

វណ្ណៈ: វត្តអីគេ?

សុខខឿនៈ គេហៅវត្តស្អី ភ្លេចវត្តនឹងបាត់ទៅ វត្តស្អីគេ។ អាមួយអាវប៉ាវ៉ា បានវាដឹង។

វណ្ណៈ: មុននឹងស្លាប់នឹង គាត់ឈឺច្រើនខែទេ?

សុខខឿនៈ ឈឺយូរណាស់ ឈឺរាប់ខែ ឈឺអាចមន៍អត់ដឹង នោមអត់ដឹង ប៉ុនឈឺនឹងប៉ុនធាត់ ឈឺនៅដេកកន្ទេលនឹងដើរអត់រួច ទន់រលេះរលាក់ដូចកូនង៉ែតចឹង។

វណ្ណៈ: ដល់ហើយទៅបានស្លាប់ទៅ?

សុខខឿនៈ ចា៎!

វណ្ណៈ: គេចាក់ថ្នាំឲ្យស្លាប់ទេ មើលទៅដូចវេទនាពេក?

សុខខឿនៈ អត់ទេ កាលឆ្នាំនឹង ដូចអត់មានចាក់ថ្នាំផង កាលនឹងយួនបុកនៅ១០០៣នឹង នាំគ្នាភៀសទៅមុខអស់។ ដល់កន្លែងផ្ទះចាស់នឹងអត់មានអ្នកណានៅទេ នៅតែគាត់នឹង ផ្ទះគាត់ៗទៅអត់រួចនឹងគេឲ្យនៅនឹង។ ពួកខ្ញុំអីទៅ គេទៅប្រាញ់អស់ហើយ។ ពេលយួនបុក នាំគ្នារត់មកក្រោយវិញ បានគេថាតាវ៉ែនស្លាប់បាត់ហើយ អត់ទៅនាំគ្នាជួយដាំបាយដាំទឹកអីទេ។ នាំគ្នាថាមិនបានទៅទេ អាឡែងរត់យួនរៀបចំអីវ៉ាន់រញ៉េរញ៉ៃ អត់បានទៅមើល។

វណ្ណៈ: ឆ្នាំណាតាវ៉ែនស្លាប់?

សុខខឿនៈ តាវ៉ែនស្លាប់ឆ្នាំប៉ុន្មានទេ។

វណ្ណៈ: មីងអត់ទាន់ការដែរ?

សុខខឿនៈ ខ្ញុំអត់ទាន់ការផង។

វណ្ណៈ: ៨០ជាងតិចតួច។ តាម៉ុកមានមើលថៃ មានមកមើល?

សុខខឿនៈ អត់ទេ។

វណ្ណៈ: តាម៉ុកស្អប់ម៉ង?

សុខខឿនៈ ចា៎! នៅកន្លែងជិតគ្នានឹង គាត់អត់ដែលមកមើលទេ។

វណ្ណៈ: តែប្រពន្ធគាត់នៅរស់រាល់ថ្ងៃ?

សុខខឿនៈ ប្រពន្ធគាត់នៅរាល់ថ្ងៃ។ យកប្រពន្ធទៀតដឹង។

វណ្ណៈ: យកប្ដីទៀត?

សុខខឿនៈ ហើយ យកប្ដីទៀតហើយដឹង។

វណ្ណៈ: គាត់មានកូនចៅច្រើន?

សុខខឿនៈ មាន នៅ១០០៣។

វណ្ណៈ: មីងកាលការឆ្នាំ៨៥ មីងការនឹងដូចថាមានចាប់ដាគូ ឬក៏រៀបការតាមប្រពៃណី?

សុខខឿនៈ រៀបការ អត់ចាប់ដាគូផង ។

វណ្ណៈ មានភ្លេង មានអីដែរ មានអាចារ្យ មានលោកសង្ឃដែរ?

សុខខឿនៈ កាលនោះមានតើ អាចារ្យមាន ប៉ុនភ្លេងអត់មាន យើងចាក់ជាម៉ាញ៉ េ អត់មានភ្លេងមានអី ទេកាលនឹង ។

វណ្ណៈ យើងចាក់ការនៅកន្លែងណា?

សុខខឿនៈ វត្តអូររំចេកនឹង ។

វណ្ណៈ ចាក់ម៉ាញ៉េ អត់មានជាអ័រគេសទេ?

សុខខឿនៈ អត់ ។

វណ្ណៈ អូររំចេក?

សុខខឿនៈ ចា៎!

វណ្ណៈ អូររំចេកនៅកន្លែងណា?

សុខខឿនៈ នៅជិតសំឡូតនេះ ។

វណ្ណៈ ជិតសំឡូតដែរ?

សុខខឿនៈ ចា៎!

វណ្ណៈ មីងអត់ដែលបានទៅសំឡូត?

សុខខឿនៈ អត់ដែលផង ។

វណ្ណៈ ចុះមីងការហើយចឹង គ្រួសារនៅតែតស៊ូទៅមុខទៀតទៅ?

សុខខឿនៈ ចា៎!

វណ្ណៈ ហើយមីងនៅដឹកជញ្ជូន?

សុខខឿនៈ ខ្ញុំនៅក្រោយ នៅដឹកជញ្ជូន ។

វណ្ណៈ ចុះហើយទៀត ដូចថា មីងម៉េចបានអត់រត់ទៅថៃ ទៅអី?

សុខខឿនៈ ដូចអត់បារម្ភចង់ទៅថៃ អត់ចិត្ត អត់ចង់ទៅ ។

វណ្ណៈ អត់ចង់ទៅស្រុកក្រៅ ទៅស្រុកអី?

សុខខឿនៈ ចា៎!

វណ្ណៈ ចឹងមីងនៅនឹងមានចូលទៅថៃក្រោយមក បានមីងចូលមកភូមិឃុំនេះឆ្នាំ៩០ជាង?

សុខខឿនៈ ខ្ញុំ ពីមុនខ្ញុំនៅថ្មដារយើងជិតថៃនឹង ។

វណ្ណៈ បាទ! នៅនឹងរហូត ដល់សមាហរណកម្មហើយបានមកនេះ?

សុខខឿនៈ ចា៎!

វណ្ណៈ មករស់នៅនឹងសមាហរណកម្មហើយ?

សុខខឿនៈ ខ្ញុំនៅនេះ នៅថ្មដាររនឹងហើយបានខ្ញុំទៅនៅ១០០៣នោះ។

វណ្ណៈ ១០០៣កន្លែងណា?

សុខខឿនៈ នៅកន្លែងតាម៉ុក នៅ១០០៣។

វណ្ណៈ អន្លង់វែង?

សុខខឿនៈ ចា៎!

វណ្ណៈ ឆ្នាំណាទៅអន្លង់វែង?

សុខខឿនៈ អន្លង់វែងទៅ ឆ្នាំ២០០០ហើយនឹង ដឹងឆ្នាំប៉ុន្មានទេ។

វណ្ណៈ សមាហរណកម្មហើយនៅ?

សុខខឿនៈ សមាហរណកម្មហើយខ្ញុំទៅ។

វណ្ណៈ ទៅអន្លង់វែងបានប៉ុន្មានឆ្នាំ មកវិញ?

សុខខឿនៈ ខ្ញុំទៅបានម៉ាឆ្នាំ។

វណ្ណៈ មកនៅនឹង?

សុខខឿនៈ ចា៎! មកនៅអូររំចេកនេះវិញ។ ខ្ញុំនេះកាលបងបូរាណ គាត់អត់ទាន់ស្លាប់ ខ្ញុំនៅនេះ។ ពេលដល់គាត់ស្លាប់ ខ្ញុំទៅនៅ១០០៣វិញ។

វណ្ណៈ ចុះមីងនៅ១០០៣ តាំងពីឆ្នាំ៨៣ ការនៅសំឡូតទេ អឺ!ការនៅអន្លង់វែង?

សុខខឿនៈ ការនៅអូររំចេកនេះនឹង។

វណ្ណៈ អូររំចេកនៅណាវិញ?

សុខខឿនៈ នេះ អូររំចេកសំឡូតយើងនេះ។

វណ្ណៈ ចុះមីងថាទៅ១០០៣ អន្លង់វែងឆ្នាំណា?

សុខខឿនៈ ទៅ.....ដឹងទៅឆ្នាំណា។

វណ្ណៈ ចុះមីងថាក្រោយសមាហរណកម្មហើយ?

សុខខឿនៈ ចា៎!

វណ្ណៈ ដល់ពេលហើយមកពីអន្លង់វែង មកនៅនឹងដដែល?

សុខខឿនៈ ចា៎! មកពីអន្លង់វែង មកនៅអូររំចេកនេះ។ ចេញពីអូររំចេកនៅទៅនៅឱរ៉ាល់។

វណ្ណៈ ឱរ៉ាល់កំពង់ស្ពឺនឹង?

សុខខឿនៈ ចា៎! ខ្ញុំចេញពីអូររំចេកទៅការហើយ ខ្ញុំចុះទៅនៅឱរ៉ាល់។ ពេលឱរ៉ាល់ទាហានបុកខ្លាំងពេក បានខ្ញុំឡើងមកនៅយើងនឹង។

វណ្ណៈ	ចឹងមីនិយាយច្រឡំហើយ ។ ចាំមើល ខ្ញុំចង់និយាយថា អាឆ្នាំសម័យតស៊ូ ដូចតស៊ូជាមួយវៀតណាម តស៊ូអី យើងតស៊ូរហូតដល់ឆ្នាំ៨០ជាង ៨៨ ៨៩វៀតណាមដក ។ សល់វៃខ្មែរនិងខ្មែរទេ ដល់ពេលមីងនឹងនៅខាងថ្មដានឹងរហូត?

សុខខឿនៈ ចា៎! វៃយួននឹង ខ្ញុំនៅថ្មដារ ។

វណ្ណៈ	ចុះដល់ពេលខាងខ្មែរក្រហមចុះចូលជាមួយរដ្ឋាភិបាល អ៊ីនគាត់ ចូលមក មីងនៅណាវិញ?

សុខខឿនៈ នឹងខ្ញុំនៅនេះ យើងនៅនឹងហើយ ប៉ុននៅភូមិចាស់នោះ ។

វណ្ណៈ	អូនៅនឹងដែរ?

សុខខឿនៈ ចា៎! ប៉ុននៅភូមិចាស់ ។

វណ្ណៈ	អ៊ីនគាត់ចូលមកនឹង មីងនៅនឹងដដែលទេ?

សុខខឿនៈ ចា៎!

វណ្ណៈ	បើសមាហរណកម្មហើយ មានដូចថាយើងចេញចូលក្រៅបាន ផានឹងបានមីងទៅអន្លង់វែង ឬក៏អត់?

សុខខឿនៈ ខ្ញុំទៅអន្លង់វែង មើលខ្ញុំទៅអន្លង់វែងតាំងពីឆ្នាំយើង ខ្មែរ ហើយនឹងខ្មែរវៃគ្នា ខ្ញុំនៅអន្លង់វែង ។ ដល់ចេញពីអន្លង់វែងមក មិនខ្មែរនិងខ្មែរវៃគ្នាទៀត មកនៅអូររំចេកចុះទៅឱរ៉ាល់ឡើងពីឱរ៉ាល់មកៗនៅនឹងវិញ ។

វណ្ណៈ	ទៅឱរ៉ាល់ទៅធ្វើអី?

សុខខឿនៈ កាលនឹង អង្គភាពគេចុះទៅនៅឱរ៉ាល់ យើងទៅនៅឱរ៉ាល់នឹង ទៅធ្វើស្រែ ធ្វើអីបានម៉ាឆ្នាំ ៧ដែរ ។

វណ្ណៈ	ហើយបានមកនៅនឹងវិញ?

សុខខឿនៈ ចា៎!

វណ្ណៈ	នៅនេះរហូតទៅ?

សុខខឿនៈ មកនេះ ។

វណ្ណៈ	មកនៅនេះ មកឈរជើង ធ្វើផ្ទះសម្បែងឆ្នាំណា?

សុខខឿនៈ ឆ្នាំណា ។

វណ្ណៈ	មីងនេះប៉ុន្មាន?

សុខខឿនៈ ១០ឆ្នាំជាង ។

វណ្ណៈ	ចឹងឆ្នាំ៩០ជាងមីងនៅនេះ?

សុខខឿនៈ ចា៎! ខ្ញុំនៅភូមិចាស់នោះ កាលអត់ទាន់កើតផ្លូវនៅភូមិចាស់ខាងក្នុង ។

វណ្ណៈៈ ចឹងខ្ញុំចង់សួរតិចទៀត ដូចថាកាលសម័យតស៊ូ មកដល់ឥឡូវនេះ មីងគិតថាមួយណាស្រួល រស់នៅជាង?

សុខខឿនៈ រាល់ថ្ងៃនឹងស្រួលរស់នៅជាង វាមានផ្លូវមានរដ្ឋាភិបាល ដឹកនាំយើងដឹងខុស ដឹងត្រូវ ដល់ ចឹងទៅយើងចេះតែយល់ ចេះតួនាទីផ្លូវការងារអីយើងធ្វើមិនសូវស្មុគស្មាញ ។

វណ្ណៈៈ ចឹងមីងដូចថាកន្លងមកមីងដែលស្តាប់វិទ្យុរឿងកាត់ទោសកាត់អីទេ មីងដែលស្តាប់ទេ?

សុខខឿនៈ ស្តាប់តើប្អូន ។

វណ្ណៈៈ មីងយល់យ៉ាងម៉េចដែរ តុលាការកាត់ទោសសព្វថ្ងៃនឹង?

សុខខឿនៈ ដូចគេធ្វើកាត់ទោសនឹងវាស្រួលម្យ៉ាងដែរនឹង មេខ្មែរក្រហមវាធ្វើសកម្មភាពណាមួយវាខុស គេកាត់ទោសយើង ។

វណ្ណៈៈ ចឹងមីងដូចថាកាលដែលធ្វើឲ្យប្រជាជនស្លាប់ មីងធ្វើការលំបាកវេទនានឹង មីងគិតថាថ្នាក់លើ បញ្ជាមក ឬក៏ថ្នាក់ក្រោមចេះតែធ្វើខ្លួនឯង?

សុខខឿនៈ កាលពីសម័យ៣ឆ្នាំ?

វណ្ណៈៈ កាលសម័យ៣ឆ្នាំ?

សុខខឿនៈ គិតទៅខ្ញុំ បើខ្ញុំអត់មានយល់ថាពីខាងលើមកទេ ខាងថ្នាក់ក្រោមនឹងចឹងម៉ង ។ ព្រោះថ្នាក់លើ គាត់ណែនាំយើងឲ្យ ដូចឧទាហរណ៍កន្លែងខ្ញុំម៉ង បានខ្ញុំថាមិនមែនពីខាងលើៗ ឧទាហរណ៍ថា គាត់ចុះមកចឹង រឿងហូបចុក ដូចជាម្ហូបអាហារបាយទឹកអី គាត់ឲ្យដាំឲ្យអីហូបត្រឹមត្រូវ ពេលគាត់ទៅបាត់ ខាងក្រោមនេះ គេចាប់ផ្តើមធ្វើជាបបរ ធ្វើអីចឹងទៅ ។ ចឹងបានខ្ញុំថាមិន មែនជាខាងលើទេធ្វើចឹង មានថ្នាក់ក្រោមទេធ្វើ ។

វណ្ណៈៈ មីងយល់ចឹង?

សុខខឿនៈ ចា៎!

វណ្ណៈៈ ប៉ុនមកដល់ឥឡូវនេះ គេកាត់ទោសថ្នាក់ដឹកនាំកំពូលធំៗនឹង មីងយល់ស្របដែរ ឬក៏មិន យល់ស្របទេ?

សុខខឿនៈ ខ្ញុំយល់ស្របតាមនឹងដែរ តាមគេកាត់ទោសនឹងដែរ ។

វណ្ណៈៈ កាត់ទោសនឹង ដើម្បីដឹងថា អ្នកណាធ្វើខុស អ្នកណាធ្វើត្រូវមីងនេះ?

សុខខឿនៈ ចា៎ៗ ។

វណ្ណៈៈ ចុះរាល់ថ្ងៃ ប្រជាជននៅភូមិយើងនឹង ដូចថាប្រកបមុខរបរអីច្រើនជាងគេ?

សុខខឿនៈ ស្រុកនឹង ធ្វើចំការទេប្អូន ។

វណ្ណៈៈ ធ្វើចំការ ដូចជាស្ពៃខ្វះ សណ្តែក ពោត?

សុខខឿនៈ សណ្ដែក ពោត ល្ង ស្រូវ។

វណ្ណៈ ហើយនាំចូលទៅលក់ទៅថៃ ទៅអីចឹងទៅ?

សុខខឿនៈ ចា៎! ស្រុកថៃ ស្រុកយួន។

វណ្ណៈ ទៅយួនដែរ?

សុខខឿនៈ ចា៎! យួន។

វណ្ណៈ បាទ! ចឹងខ្ញុំអរគុណមីងច្រើន ដែលបានផ្ដល់បទសម្ភាសន៍ អរគុណមីងច្រើន។

សុខខឿនៈ ចា៎!ឥ

«ចប់»